លេខ ១៣
ឆ្នាំ២០២២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ ១៣

# បុព្វកថា

នៅក្នុងបរិការណ៍ឆ្នាំ២០២១, ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ដ៏កាចសាហាវបាននិងកំពុងបន្តនាំមកនូវផលប៉ះពាល់អវិជ្ជមានបញ្ហាប្រឈម និងហានិភ័យជាច្រើនដែលមិនធ្លាប់មានពីមុនមកចំពោះតំបន់និងពិភពលោកទាំងមូលដោយគ្មានការលើកលែងចំពោះប្រទេសណាមួយឡើយ ជាពិសេសគឺបានធ្វើឱ្យមនុស្សរាប់លាននាក់បាត់បង់ការងារ ធ្លាក់ចុះនូវប្រាក់ចំណូល ហើយប្រជាជនមួយចំនួនធំនៅលើពិភពលោក ត្រូវធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ ហើយកម្ពុជាក៏មិនអាចគេចរួចពីផលវិបាកដ៏អាក្រក់ទាំងនេះផងដែរ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គមសេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ តែថែមទាំងអាចទាញបង្អន់ល្បឿននៃកិច្ចដំណើរការអភិវឌ្ឍឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេលនៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ផងដែរ។

ឆ្លងកាត់ដំណាក់កាលដ៏លំបាកនេះ ទោះបីកម្ពុជាជាប្រទេសតូច ហើយធនធានក៏នៅមានកម្រិតក្តី ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានៅរក្សាបានស្ថានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាព នៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងការវិភាជឡើងវិញនូវចំណាយក្នុងឆ្នាំ, រាជរដ្ឋាភិបាលមានសមត្ថភាពនិងលទ្ធភាពអាចគ្រប់គ្រងសភាពការណ៍វិបត្តិនៃជំងឺកូវីដ-១៩បានល្អប្រសើរឆ្លើយតបបានទៅនឹងកិច្ចការអាទិភាពដែលកើតមានថ្មីៗ ដោយផ្អែកលើមូលដ្ឋានគ្រឹះ រឹងមាំនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលយើងខិតខំកសាងបាននៅក្នុងរយៈពេលជាង ២ទសវត្សរ៍កន្លងមក ជាពិសេសក្នុងរយៈពេល ៧ឆ្នាំចុងក្រោយ ព្រមជាមួយនឹងការចូលរួម យ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធរួមទាំងដៃគូអភិវឌ្ឍន៍ ផ្នែកការវិស័យឯកជន ព្រមទាំងអង្គការ និងសង្គមស៊ីវិលផងដែរ។ លើសពីនេះ ជាមួយនឹងកិច្ចប្រឹងប្រែងតស៊ូជម្នះនឹងវិបត្តិនៃជំងឺកូវីដ-១៩, សំដៅកាត់បន្ថយផលប៉ះពាល់ នៃវិបត្តិនេះមកលើសុខភាព ជីវភាពរស់នៅរបស់ប្រជាជន និងសង្គមសេដ្ឋកិច្ចទាំងមូល។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏បានគិតគូររៀបចំនូវ "ផែនការស្តារសេដ្ឋកិច្ចឡើងវិញ" សម្រាប់ឆ្នាំ២០២១-២០២៣ ដែលជាការត្រៀមខ្លួន សម្រាប់ដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩ (Post Covid-19) ដើម្បីឈានទៅបង្កើតបាននូវភាពធន់ (Resiliency) របស់កម្ពុជា ទៅនឹងវិបត្តិសម្រាប់រយៈពេលវែងខាងមុខ រួមបញ្ចូលនូវវិបត្តិសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ និងការរាតត្បាតនៃជំងឺឆ្លងនានាផងដែរ។

សមិទ្ធផលដែលសម្រេចបានមកដល់ពេលនេះ គឺដោយសារការចូលរួមយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវក្នុងភាពជាម្ចាស់របស់ក្រសួង-ស្ថាប័ន ព្រមទាំងមានការគាំទ្រជាប្រចាំ និងការប្តេជ្ញាចិត្តឥតងាករេពីថ្នាក់ដឹកនាំ និងស្ថាបនិកគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងរូបខ្ញុំផ្ទាល់សូមធ្វើការវាយតម្លៃខ្ពស់និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ននិងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាសេនាធិការ ជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងការងារដឹកនាំ សម្របសម្រួល គាំទ្រ ផ្សព្វផ្សាយ ត្រួតពិនិត្យ ព្រមទាំងវាយតម្លៃ ប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម៕ ៚

ថ្ងៃ អង្គារ ៣ កើត ខែ មិគសិរ ឆ្នាំខាល ត្រីស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ ១៣

# អារម្ភកថា

បន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះស្របជាមួយនឹងការរងផលប៉ះពាល់នៃសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន និងបញ្ហាវិបត្តិសេដ្ឋកិច្ចសកលនាពេលបច្ចុប្បន្ន, ប្រទេសកម្ពុជានៅតែអាចរក្សាបាននូវប្រក្រតីភាព និងការអភិវឌ្ឍក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងកំឡុងពេលមានវិបត្តិនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាចំណែកមួយយ៉ាងសំខាន់ក្នុងការគាំទ្រនិងពង្រឹងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាដែលឆ្លុះបញ្ចាំងពីភាពបន់បែនយ៉ាងឆាប់រហ័សនៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រភាពធន់នៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនិងចីរភាពនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាការពិត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅលើមាគ៌ា និងទិសដៅត្រឹមត្រូវដែលយើងអាចរក្សាបាននូវភាពជាម្ចាស់ទាំងស្រុង ហើយរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានជ្រើសរើសអភិក្រមប្រតិបត្តិ ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបានជាពិសេសដែលផ្ដល់នូវលទ្ធផលជាក់ស្ដែងជាបន្តបន្ទាប់នៅតាមដំណាក់កាលនីមួយៗ។ បន្ថែមពីនេះប្រព័ន្ធថវិកាយើងកាន់តែមានភាពជឿទុកចិត្ត និងជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

រហូតមកដល់ពេលនេះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដំណើរការអស់រយៈពេលជិតពីរទសវត្សរ៍មកហើយគឺចាប់ពីឆ្នាំ២០០៤ និងកំពុងស្ថិតនៅដំណាក់កាលទី៣ បូក២ មុនឈានចូលដល់ដំណាក់កាលទី៤ ព្រមទាំងទទួលបានការគាំទ្រ និងចូលរួមអនុវត្តយ៉ាងផុសផុលពីគ្រប់ស្ថាប័នព្រមទាំងអង្គភាពនៃរាជរដ្ឋាភិបាលហើយសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងទាំងនេះក៏ទទួលបានការសាទរ និងកោតសរសើរពីសាធារណជនទូទៅ ព្រមទាំងដៃគូអភិវឌ្ឍន៍ផងដែរ។ ដូចនេះដើម្បីបន្តលើកកម្ពស់ការយល់ដឹង និងការគាំទ្រដល់ទិសដៅ និងចក្ខុវិស័យ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា អ.គ.ហ. ដែលជាសេនាធិការឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែបន្តបេសកកម្មរបស់ខ្លួនឥតងាករេក្នុងការបញ្ជ្រាបការយល់ដឹងថ្មីៗបន្ថែមក៏ដូចជាផ្សព្វផ្សាយនូវសមិទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់ តាមរយៈការបណ្ដុះបណ្ដាល សិក្ខាសាលា ការផ្សព្វផ្សាយ និងកិច្ចប្រជុំនានា។

ជាក់ស្ដែង សម្រាប់ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ១៣នេះនឹងចងក្រងនូវបច្ចុប្បន្នភាពនៃព្រឹត្តិការណ៍ អត្ថបទសុន្ទរកថានិងទស្សនៈនិងមតិរបស់ថ្នាក់ដឹកនាំសំខាន់ៗដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានតម្លៃជាច្រើនអាចផ្ដល់ជាប្រយោជន៍បន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជនដែលចង់ឈ្វេងយល់អំពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល៕ ✍

ថ្ងៃ អង្គារ ១២រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០២២

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

*ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ ១៣ ឆ្នាំ២០២២*

## ព្រឹត្តិការណ៍


### ទំព័រ ១

ការពិភាក្សានិងផ្តល់អនុសាសន៍លើការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤នៃកម្មវិធីកែទម្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣-២០២៧

### ទំព័រ ៣

កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ បូក២

### ទំព័រ ៩

វិបស្សនារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រង និងការអនុវត្តចំណាយថវិកានៅរដ្ឋបាលថ្នាក់ជាតិ ហើយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ទំព័រទី ១១

កិច្ចពិគ្រោះយោបល់ស្តីពីការស្ទាបស្ទង់ទីផ្សារអំពីតម្រូវការមូលបត្ររដ្ឋ

### ទំព័រ ១៣

សិក្ខាសាលាស្តីពីបទពិសោធនៃការអនុវត្តថវិកាកម្មវិធីថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ


## អត្ថបទ


### ទំព័រ ១៧

អាទិភាព និងក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣-២០២៧

### ទំព័រ ២០

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្តីពីការរៀបចំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងបរិបទឌីជីថលនីយកម្មនៅកម្ពុជា

### ទំព័រ ២២

ការត្រៀមដាក់ឱ្យដំណើរការប្រព័ន្ធឯកសារឌីជីថល(FMIS Portal) ជំនាន់ទី១ ទៅកាន់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ

### ទំព័រ ២៤

ជំនាញការIMF: ប្រព័ន្ធFMIS គឺជាកតាលីករដ៏សំខាន់បំផុតក្នុងការជំរុញល្បឿននៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យបានទៅដល់គោលដៅ និងការពង្រឹងការអនុវត្តច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនៅកម្ពុជា

### ទំព័រ ២៦

"លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ក្នុងកិច្ចការគ្រប់គ្រងនិងការប្រមូលចំណូលពន្ធដារ"

### ទំព័រ ២៨

មុខងារសវនកម្មផ្ទៃក្នុងនៅក្នុងបរិបទបច្ចេកវិទ្យាព័ត៌មាន

### ទំព័រ ៣០

បច្ច័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើការចូលរួមកែលម្អប្រព័ន្ធហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈ

### ទំព័រ ៣៣

សញ្ញាណទូទៅនៃវិធីសាស្ត្រវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ(MAPS)


## សុន្ទរកថា


### ទំព័រ ៣៧

សុន្ទរកថាឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី គោលនយោបាយ និងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

### ទំព័រ ៤៥

សុន្ទរកថាឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើគោលនយោបាយនិងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព. ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២


## ទស្សនៈ និងមតិ


### ទំព័រ ៥១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២២ ក្រោមប្រធានបទ"ការស្តារកម្ពុជាឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ ÷ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព បន្ទាប់ពីជំងឺកូវីដ-១៩" សណ្ឋាគារសុខាភ្នំពេញ, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២

### ទំព័រ ៥១

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងសុន្ទរកថាក្នុងពិធីបើក"ទិវាសប្តាហ៍គាំពារសង្គម" ប្រចាំឆ្នាំ២០២២ នៅសណ្ឋាគារ Hyatt Regency ភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២

### ទំព័រ ៥២

ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលថ្លែងសុន្ទរកថារាយការណ៍ក្នុង"សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើគោលនយោបាយ និងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា" នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

### ទំព័រ ៥២

លោកជំទាវបណ្ឌិត **ជា សិរី** ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជាថ្លែងក្នុងសិក្ខាសាលាតម្រង់ទិសអំពី"កម្មវិធីលទ្ធភាពទទួលបានហិរញ្ញវត្ថុ" នៅសណ្ឋាគារ អូឡាំព្យាស៊ីធី និងតាមប្រព័ន្ធអនឡាញ, ថ្ងៃទី១ ខែមេសា ឆ្នាំ២០២២




ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ ១៣

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ផ្នែកទី ១

# ព្រឹត្តិការណ៍



# ការពិភាក្សានិងផ្ដល់អនុសាសន៍លើការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣-២០២៧

*នាថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) បានដឹកនាំក្នុងកិច្ចប្រជុំប្រចាំឆ្នាំដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងសមាជិក គ.ហ.ស. ព្រមទាំងដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ៣ បូក ២ (CAP3+2) ឆ្នាំ២០២១ និងពិភាក្សាពីអាទិភាព សម្រាប់អនុវត្ត CAP3+2 ឆ្នាំ២០២២ ព្រមទាំងអាទិភាពសម្រាប់បញ្ចូលក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៤ (CAP4) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣-២០២៧។*



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ក្នុងពេលពិភាក្សាពីអាទិភាពនិងក្របខណ្ឌCAP4, អង្គប្រជុំបានរំលឹក (reiterate) ពីគោលបំណងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសង្កត់ធ្ងន់លើការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការរៀបចំនិងការអភិវឌ្ឍប្រព័ន្ធក្របខណ្ឌគតិយុត្តយន្តការនិងធនធានមនុស្សដើម្បីកែលម្អដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យអាចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងអាចគាំទ្រដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ អង្គប្រជុំពិនិត្យឃើញថា ការកំណត់អាទិភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣-២០២៧ត្រូវផ្ដល់ការយកចិត្តទុកដាក់សិក្សាលើកត្តា២គឺ÷ (ទី១) តម្រូវការនៃប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងបរិការណ៍អភិវឌ្ឍន៍បច្ចុប្បន្ន។ (ទី២)លទ្ធភាពជាក់ស្ដែងក្នុងការកែទម្រង់សមាសធាតុនិងមុខងាររបស់ប្រព័ន្ធ។

***ដ្យាក្រាមទី ១÷ អភិក្រមនៃការកំណត់អាទិភាពកែទម្រង់:*** ជាអភិក្រមនិងវិធីសាស្ត្រនៃការរៀបចំ CAP4, អង្គប្រជុំបានណែនាំឱ្យមានការស្នើសុំជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ដើម្បីធ្វើការសិក្សាពីប្រតិបត្តិការនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈហើយផ្ដល់ធាតុចូលនិងមតិយោបល់លើអាទិភាពនៃទិសដៅកែទម្រង់ CAP4។ ម្យ៉ាងទៀត ក្នុងនាមជាសេនាធិការ, អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ





***ដ្យាក្រាមទី ១÷ អភិក្រមនៃការកំណត់អាទិភាពកែទម្រង់***




ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ត្រូវវាយតម្លៃពីលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ទាំង៥ និង CAP 3+2 ហើយពិនិត្យលទ្ធភាពបញ្ចូលមតិយោបល់របស់ដៃគូអភិវឌ្ឍន៍សម្រាប់CAP4ដោយផ្អែកតាមទម្រង់ដែលមានស្រាប់។

***ដ្យាក្រាមទី ២÷ វិធីសាស្ត្រនៃការរៀបចំ CAP4 :*** ត្រង់ចំណុចនេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យបានផ្ដល់អនុសាសន៍ណែនាំចំនួន ៣ ចំណុច សម្រាប់រៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៤ (CAP4)÷

១- ការរៀបចំនិងអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវប្រកាន់ឆន្ទៈមោះមុតនិងប្រកបដោយមហិច្ឆតាប្រាកដនិយម។

២- ផែនការសកម្មភាពកម្រិតយុទ្ធសាស្ត្រនិងកម្រិតប្រតិបត្តិការត្រូវមានភាពប្រទាក់ក្រឡាហើយសូចនាករនិងគោលដៅនៃផែនការទាំង២កម្រិតត្រូវមានសុខុដុមនីយកម្មដើម្បីញ៉ាំងឱ្យការអនុវត្តអាចបង្កើតបាននូវសហថាមពលនិងជវភាពនៃដំណើរការរបស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៣- ទន្ទឹមនឹងការជំរុញការកែទម្រង់សមាសធាតុ (forms) និងមុខងារ (functions) នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានប្រតិបត្តិការ(operation) ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ, អ.គ.ហ. ត្រូវពិនិត្យមើលបច្ច័យនៃប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាហើយតម្រឹមទិសដៅកែទម្រង់ឱ្យមានសង្គតិភាព និងភាពឆ្លើយតបទៅនឹងតម្រូវការនៃការប្រើប្រាស់ប្រព័ន្ធសម្រាប់ស្តារនិងអភិវឌ្ឍន៍ជាតិក្នុងបរិការណ៍និងស្ថានភាពក្រោយវិបត្តិកូវីដ-១៩។

ជាចុងក្រោយ, អង្គប្រជុំបានផ្ដល់ការឯកភាពជាគោលការណ៍(endorsement) លើអភិក្រម និងវិធីសាស្ត្រ ដើម្បីធានានូវបរិយាបន្ននៃការចូលរួមពីគ្រប់តួអង្គបច្ចេកទេសពាក់ព័ន្ធហើយរក្សានូវភាពជាម្ចាស់របស់អង្គភាពអនុវត្តក្នុងការរៀបចំ CAP4 មួយដែលជាលទ្ធផលរួមសម្រាប់ជំរុញការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ ២០២៣-២០២៧ ខាងមុខ។

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធនៃ អ.គ.ហ.*

***ដ្យាក្រាមទី ២÷ វិធីសាស្ត្រនៃការរៀបចំ CAP4***



# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២

*នាព្រឹកថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទី, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដឹកនាំ "កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក ២" តាមរយៈប្រព័ន្ធវីដេអូអនឡាញ។*



កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.), អនុប្រធាននិងសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងស្ថាប័ននិងអង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី ខេត្តព្រមទាំងតំណាងសហគមន៍អឺរ៉ុប,ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ, អង្គការយូនីសេហ្វ, រដ្ឋាភិបាលបារាំង AFD, រដ្ឋាភិបាលអូស្ត្រាលី,និងស្ថាប័នអន្តរជាតិផ្សេងទៀត។ កិច្ចប្រជុំនេះប្រព្រឹត្តទៅពេញមួយថ្ងៃដោយផ្តោតកិច្ចពិភាក្សាលើរបៀបវារៈចំនួន៣ ដូចខាងក្រោម÷

**របៀបវារៈទី១**÷របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១

**របៀបវារៈទី២**÷ សេចក្តីព្រាងផែនការសកម្មភាពរួម ដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧

**របៀបវារៈទី៣**÷ ការពិនិត្យ និងអនុម័តផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រគន្លឹះទាំង៤ សម្រាប់អនុវត្តឆ្នាំ២០២២-២០២៥ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីថ្មីតាមប្រព័ន្ធ FMIS។

**របៀបវារៈទី១÷ របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១**







តាមរយៈរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងរបាយការណ៍ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១, រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគន្លឹះៗគួរឱ្យកត់សម្គាល់ដូចតទៅ÷

**ទី១).** ក្នុងក្របខណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,ការប្រមូលចំណូលនៅតែមានភាពរឹងមាំតាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨, ចំណូលចរន្តមានកំណើនជាមធ្យមប្រមាណ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ខ្ពស់ជាងគោលដៅ០,៥ពិន្ទុភាគរយនៃ ផ.ស.ស.ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រខាងលើ។ សម្រាប់ឆ្នាំ២០២១ លទ្ធផលនៃការអនុវត្តចំណូលថវិកាសម្រេចបានតាមគោលដៅក្នុងរង្វង់+/-៥%។

សមិទ្ធផលនេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចសន្សំនិងបង្ករថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាពក៏ដូចជាអាចបង្កើនយ៉ាងច្រើននូវធនធានវិនិយោគសាធារណៈក្នុងស្រុកពិសេសលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលជាប្រការជួយលើកស្ទួយមួយកម្រិតដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា។ក្នុងរយៈពេលប្រមាណ២ឆ្នាំនៃវិបត្តិជំងឺកូវីដ-១៩ កន្លងទៅ, រាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយដើម្បីជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជនក៏ដូចជាការរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជនដែលបាននឹងកំពុងបន្តទទួលរងនូវផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។

**ទី២).** ការដាក់ឱ្យអនុវត្តជាបណ្តើរៗនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ដោយបានដាក់បញ្ចូលចំណាត់ថ្នាក់ថវិកាទាំង៧, ប្លង់គណនេយ្យ និងមុខងារ, បង្កើតបានជាមូលដ្ឋានសម្រាប់ការកត់ត្រាគណនេយ្យគ្រប់ជ្រុងជ្រោយនិងអាចផលិតរបាយការណ៍ទាន់ពេល។ នៅពេលនេះ, ប្រព័ន្ធFMIS បាននឹងកំពុងអភិវឌ្ឍជំហានទី៣ ដោយបានដាក់ឱ្យអនុវត្តជាផ្លូវការនៅតាមគ្រប់ក្រសួង-ស្ថាប័ន, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥រាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត ហើយឈានទៅដាក់ឱ្យអនុវត្តនៅតាមរដ្ឋបាលរាជធានីខេត្តផងដែរ។ជាមួយគ្នានេះ, មុខងារថ្មីចំនួន២ រួមមាន មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២១។ មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅ កសហវ. និងក្រសួងកិច្ចការនារី រីឯមុខងារលទ្ធកម្មនៅកសហវ., ក្រសួងកិច្ចការនារីនិងក្រសួងព័ត៌មាន។ រីឯនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្សនិងចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន២៧។

**ទី៣).** ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័ន និងតាមបណ្តារដ្ឋបាលរាជធានីខេត្តស្របគ្នានឹងការបង្កើតនិងដាក់ឱ្យអនុវត្តអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័ន។ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីបាននាំមកនូវការកែប្រែការគ្រប់គ្រងថវិកាទាំងស្រុងដែលពីមុនមានលក្ខណៈមជ្ឈការនៅតាមក្រសួង-ស្ថាប័នទៅជាលក្ខណៈវិមជ្ឈការពោលគឺអ្នកអនុវត្តគម្រោងកម្មវិធីនិងសកម្មភាពផ្ទាល់ឬអ្នកបច្ចេកទេសបានដឹងពីថវិការបស់ខ្លួននិងអាចធ្វើសកម្មភាពក្នុងលក្ខណៈបុរេសកម្ម។ ជាការកត់សម្គាល់ក្រសួង-ស្ថាប័នមួយចំនួនបានចាប់ផ្តើមធ្វើការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នសាម៉ីដើម្បីឈានឆ្ពោះទៅពង្រឹងសមិទ្ធកម្មបន្ថែមទៀត។ លើសពីនេះ ការអនុវត្តថវិកាកម្មវិធីបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យបានកាន់តែប្រសើរដោយបែរឆ្ពោះទៅរកវិស័យអាទិភាព។

**ទី៤).** ការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS), ការបង្កើនការផ្សព្វផ្សាយឯកសារថវិកាជាសាធារណៈ, ការពង្រឹងតួនាទីស្ថាប័នសវនកម្ម និងអធិការកិច្ច,

និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាប្រចាំ។ វឌ្ឍនភាពទាំងអស់នេះបានជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព។

**ទី៥).** ការចូលរួមរបស់ក្រសួង-ស្ថាប័នក្នុងសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានការរីកចម្រើនជាលំដាប់ ជាពិសេសក្នុងការគ្រប់គ្រងចំណូល, ការរៀបចំថវិកាតាមប្រព័ន្ធថវិកាកម្មវិធី, ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ លើសពីនេះក្រសួង-ស្ថាប័នបានធ្វើការប្រែក្លាយការគ្រប់គ្រងថវិកាឱ្យមានភាពផ្សារភ្ជាប់ទៅនឹងការកែលម្អសមិទ្ធកម្មការងារ។

**ទី៦).** ការបង្កើនការផ្តល់ធនធានកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការជាក់ស្តែងនៅមូលដ្ឋាន។

**របៀបវារៈទី២÷ សេចក្តីព្រាងផែនការសកម្មភាពរួមដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧**

ក្នុងដំណើរការឆ្ពោះទៅកសាងប្រព័ន្ធគណនេយ្យភាពចំពោះសមិទ្ធកម្មដែលជាដំណាក់កាលទី៤នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, សេចក្តីព្រាងផែនការសកម្មភាពរួមដំណាក់កាលទី៤ឆ្នាំ២០២៣-២០២៧ត្រូវបានរៀបចំឡើងដោយឈរលើតថភាពជាក់ស្តែងក្នុងគោលបំណងតម្រង់ទិសការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្របតាមនិយាមជាអន្តរជាតិនិងបរិការណ៍កម្ពុជា។

*ផែនការសកម្មភាពរួមដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧នេះត្រូវបានរៀបចំឡើយដោយប្រមូលផ្តុំនូវធាតុចូលពីរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រគន្លឹះៗក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងរបាយការណ៍វាយតម្លៃពាក់ព័ន្ធដែលសហការវាយតម្លៃដោយដៃគូអភិវឌ្ឍន៍។*




ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយ និងសង្គតិភាពពេញលេញសេចក្តីព្រាងផែនការសកម្មភាពរួមដំណាក់កាលទី៤ដែលនឹងត្រូវបញ្ចប់ការរៀបចំនៅពាក់កណ្តាលឆ្នាំ២០២២នេះត្រូវដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធមុនស្នើសុំការពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាលដើម្បីដាក់ឱ្យអនុវត្តនាពេលខាងមុខ។

**របៀបវារៈទី៣ ÷ ការពិនិត្យ និងអនុម័តផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រគន្លឹះទាំង៤ សម្រាប់អនុវត្តឆ្នាំ២០២២-២០២៥ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីថ្មីតាមប្រព័ន្ធ FMIS**

ក្នុងកិច្ចខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈដោយឈរលើគោលការណ៍ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះមួយចំនួនក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីឆ្នាំ២០១៨ និងឆ្នាំ២០១៩ កន្លងទៅ ក្នុងនោះរួមមាន÷ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីថ្មីតាមប្រព័ន្ធFMIS។ ក្នុងពាក់កណ្តាលអាណត្តិនៃការអនុវត្តយុទ្ធសាស្ត្រគន្លឹះទាំងនេះដោយកិច្ចការកែទម្រង់ មួយចំណែកទទួលរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានផ្តល់អនុសាសន៍ណែនាំឱ្យតួអង្គពាក់ព័ន្ធពិនិត្យ វាយតម្លៃ និងកែសម្រួលផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រគន្លឹះទាំងនេះ សំដៅចាត់វិធានការជំរុញការអនុវត្តឱ្យសម្រេចបានតាមគោលដៅរំពឹងទុក។ ជាលទ្ធផល គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានអនុម័តលើផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រទាំងនេះសម្រាប់អនុវត្តក្នុងឆ្នាំ២០២២-២០២៥ហើយជំរុញតួអង្គពាក់ព័ន្ធឱ្យអនុវត្តតាមគោលដៅដែលបានដាក់ចេញប្រកបដោយបុរេសកម្មសកម្ម និងស្មារតីទទួលខុសត្រូវខ្ពស់។

ជារួមបើទោះជាស្ថិតក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩, សកម្មភាពកែទម្រង់នៅតែមានចលនការគួរឱ្យកត់សម្គាល់ក្នុងការឈានឆ្ពោះទៅកសាងវប្បធម៌សមិទ្ធកម្មនៅទូទាំងរាជរដ្ឋាភិបាល។ ចលនការនេះឆ្លុះបញ្ចាំងអំពីឆន្ទៈកិច្ចខិតខំប្រឹងប្រែងឥតរាថយនិងការចូលរួមពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។

*ក្នុងបរិការណ៍នេះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពគឺមូលដ្ឋានគ្រឹះដ៏ចាំបាច់បំផុត សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងការកាត់បន្ថយភាពក្រីក្រជាពិសេសធានាបាននូវស្ថិរភាពនិងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ននិងការរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា។*

ទន្ទឹមនេះ ដៃគូអភិវឌ្ឍន៍បានកោតសរសើររាជរដ្ឋាភិបាលកម្ពុជា ចំពោះវឌ្ឍនភាពប្រកដោយចីរភាពលើគ្រប់ទិដ្ឋភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈហើយកត់សម្គាល់ឃើញថាការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០២១សម្រេចបាននូវលទ្ធផលគន្លឹះៗ ជាពិសេសការគ្រប់គ្រងបាននូវសភាពការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩, ការគាំទ្រដល់ជីវភាពប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះតាមរយៈកម្មវិធីគាំពារសង្គមក៏ដូចជាគាំទ្រអាជីវកម្មនិងសហគ្រាសធុនតូច និងមធ្យម។ ដៃគូអភិវឌ្ឍន៍ប្តេជ្ញាគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងទិដ្ឋភាពជំនួយហិរញ្ញប្បទាន និងជំនួយបច្ចេកទេសនៅដំណាក់កាលបន្តបន្ទាប់។

មុននឹងបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានតម្រង់ទិសការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុង




ឆ្នាំ២០២២និងបណ្តាឆ្នាំខាងមុខ ដោយគូសបញ្ជាក់អំពីការងារអាទិភាពសំខាន់ៗដូចខាងក្រោម÷

**ទី១).** ជំរុញការអនុវត្តនិងតាមដានការអនុវត្តផែនការសកម្មភាពលម្អិតសម្រាប់ "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥", "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥", "យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥", "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥", និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS" ដើម្បីឱ្យសម្រេចបានតាមគោលដៅដែលបានដាក់ចេញប្រកបដោយជោគជ័យ និងចីរភាព។

**ទី២).** ជំរុញការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និងការកែសម្រួលអនុក្រឹត្យលេខ៨១ និង៨២(ថ្មី) ដើម្បីឈានទៅអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មឆ្នាំ២០២៥។

**ទី៣).** ជំរុញការធ្វើស្វ័យប្រវត្តិកម្មការអនុវត្តថវិកាដោយចាប់ផ្តើមពីកសហវ. និងក្រសួងបរិស្ថាន ព្រមទាំងពង្រីកការដាក់ឱ្យអនុវត្តមុខងាររៀបចំថវិកា និងមុខងារលទ្ធកម្មសាធារណៈឱ្យគ្រប់ក្រសួង-ស្ថាប័ន។

**ទី៤).** យកចិត្តទុកដាក់លើការកែលម្អគុណភាពនៃថវិកាកម្មវិធីដោយផ្តោតលើសមិទ្ធកម្ម និងដាក់ឱ្យអនុវត្តផ្លូវការនូវក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខណ្ឌថវិការយៈពេលមធ្យម។

**ទី៥).** ការពិនិត្យ និងកែលម្អនីតិវិធីអនុវត្តថវិកាទាំងក្នុងក្របខណ្ឌកសហវ. ព្រមទាំងក្រសួង-ស្ថាប័នសាមី ដោយផ្តោតជាសំខាន់លើការត្រួតពិនិត្យរបាយការណ៍លទ្ធផល/ សមិទ្ធកម្ម និងបង្កើតឧបករណ៍ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត។

**ទី៦).** កសហវ. និងក្រសួង-ស្ថាប័នសាមីត្រូវធ្វើកិច្ចសហប្រតិបត្តិការ និងកិច្ចសហការគ្នាដើម្បីកំណត់ និងជំរុញអង្គភាព ថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

**ទី៧).** គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការរៀបចំនិងបង្កើតអង្គភាពថវិកា ដោយត្រូវធ្វើការត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកា, ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងការកសាងសមត្ថភាព។

**ទី៨).** ពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដោយការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀតតាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្តដែលក្នុងនោះថ្នាក់ដឹកនាំឬថ្នាក់គ្រប់គ្រង ទទួលខុសត្រូវចំពោះសមិទ្ធកម្មឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត។ ចំណែកការទទួលខុស-ត្រូវផ្នែកហិរញ្ញវត្ថុត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃក្រសួង-ស្ថាប័ន។

**ទី៩).** ជំរុញការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ។

**ទី១០).** បន្តជំរុញការតម្រឹមប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងប្រព័ន្ធថវិកាថ្នាក់ជាតិដោយធានាឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយពិសេសគោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណងឬអាទិភាពគោលនយោ-បាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី, សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិកែលម្អ និងផ្លាស់ប្តូរជាជំហានៗនៃវដ្តថវិការដ្ឋបាលរាជធានី-ខេត្ត, ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិពិសេសកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវ នៅក្នុងដំណាក់កាលទាំង៤នៃវដ្តថវិកា; និងការរៀបចំប្រព័ន្ធនិងការគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិដោយត្រូវតម្រឹមជាមួយនឹងថ្នាក់ជាតិ និងប្រើប្រាស់ចំណាត់ថ្នាក់ថវិកា, ប្លង់គណនេយ្យនិងទម្រង់របាយការណ៍ដូចគ្នា។

**ទី១១).** បន្តពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងផ្ទៃក្នុងកសហវ. ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីទ្រទ្រង់ដល់ការងារកែទម្រង់ផងនិងដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តកិច្ចការប្រចាំថ្ងៃផងដែរ។

**ទី១២).** ការយកចិត្តទុកដាក់បានខ្លាំងក្លាថែមទៀតលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដោយជំរុញការអនុវត្តSARMIS និងផែនការមេសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**ទី១៣).** អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សហការជាមួយដៃគូអភិវឌ្ឍន៍ត្រូវពិនិត្យឡើងវិញនិងបូកសរុបការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២ និងរៀបចំផែនការសកម្មភាពរួមសម្រាប់ដំណាក់កាលទី៤ ដោយផ្តោតលើខឿនទី៤ គឺគណនេយ្យភាពសមិទ្ធកម្ម។

ជាចុងក្រោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ណែនាំដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទកសហវ. រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្តឱ្យបន្តកិច្ចសហការល្អ និងយកស្មារតីនៃកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២នេះដើម្បីបន្តជំរុញការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យសម្រេចបានវឌ្ឍនភាពតាមការរំពឹងទុក។

ឯកឧត្តម **អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះគ្រប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃកសហវ. និងក្រសួង-ស្ថាប័នចំពោះការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងសម្រេចបានការងារនាពេលកន្លងមក ជាពិសេសការបន្តគាំទ្រឥតឈប់ឈររបស់ដៃគូអភិវឌ្ឍន៍ក្នុងទិដ្ឋភាពជំនួយហិរញ្ញប្បទាននិងជំនួយបច្ចេកទេស ព្រមទាំងជូនពរគ្រប់ថ្នាក់ដឹកនាំមន្ត្រីរាជការទាំងអស់ និងដៃគូអភិវឌ្ឍន៍ជួបប្រទះតែនឹងពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃនៃ អ.គ.ហ.*



# វិបស្សនារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រង និងការអនុវត្ត ចំណាយថវិកានៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

*នាថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០៩:០០នាទីព្រឹក, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានសម្របសម្រួលរៀបចំកម្មវិធីវិបស្សនាប្រចាំឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) ក្រោមការដឹកនាំរបស់ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ* ***អូន ព័ន្ធមុនីរ័ត្ន*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ ជាអនុរដ្ឋលេខាធិការថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទ កសហវ. និងមន្ទីរ សហវ. រាជធានី ខេត្ត តាមប្រព័ន្ធវីដេអូអនឡាញ។*

វិបស្សនាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកទីមួយនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងវាយតម្លៃលើការអនុវត្តចំណាយថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិដើម្បីចាត់វិធានការកែលម្អសំដៅធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាពនិងចីរភាពនៃការអនុវត្តថវិការដ្ឋ។វិបស្សនានេះផ្តោតលើរបៀបវារៈចំនួន៤ រួមមាន÷

(ទី១) ការគ្រប់គ្រង និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ

(ទី២) ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរដ្ឋបាលថ្នាក់ជាតិ

(ទី៣) ការគ្រប់គ្រង និងការអនុវត្តចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

(ទី៤) ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរដ្ឋបាលថ្នាក់ក្រោមជាតិ។




ចំណូលថវិការដ្ឋ (ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) ឆ្នាំ២០២០ អនុវត្តបានចំនួន ៣០,៦៧៦,០១៩ លានរៀល ស្មើនឹង ២៨,១៣% នៃ ផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ ៦% ដោយក្នុងនោះថវិកាថ្នាក់ជាតិសម្រេចបាន ២៨,៥០០,៣៧៣ លានរៀល ស្មើនឹង ២៦,១៣% នៃ ផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ ៦,២% និងថ្នាក់ក្រោមជាតិសម្រេចបាន២,១៧៥,៦៤៦លានរៀល ស្មើនឹង ១,៩៩% នៃ ផ.ស.ស. គឺទាបជាងច្បាប់ហិរញ្ញវត្ថុ ៣%។ ចំណែកឯឆ្នាំ២០២១តាមរយៈការប៉ាន់ស្មានចំណូលថវិការដ្ឋនឹងសម្រេចបាន២៧,៧៦៨,៧៤២ លានរៀល ស្មើនឹង ២៥,៩៥% នៃ ផ.ស.ស. គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ៣,៧%។ លទ្ធផលនៃការអនុវត្តចំណូលថវិកានិងចំណាយថវិកាបង្ហាញថានៅឆ្នាំ២០២០ មានឱនភាពថវិកាសរុប ៧,៦៣០,៨៦៩ លានរៀល








ស្មើនឹង ៧% នៃ ផ.ស.ស. និងឆ្នាំ២០២១ មានឱនភាពថវិកាសរុប១០,៨២៤,៤៩៨ លានរៀលស្មើនឹង៩,៧៥%នៃផ.ស.ស.។

ក្នុងដំណើរការថវិកានៅរដ្ឋបាលថ្នាក់-ជាតិជួបប្រទះបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធជាមួយកំណើនតម្រូវការថវិកាប្រចាំឆ្នាំ, សមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធ និងយន្តការសម្របសម្រួល។ បញ្ហាបម្រែបម្រួលអាកាសធាតុបានធ្វើឱ្យតម្លៃគម្រោងកើនឡើងនិងមានតម្រូវការបច្ចេកទេសខ្ពស់។ទន្ទឹមនេះកិច្ចលទ្ធកម្មសាធារណៈនៅបន្តចោទជាបញ្ហាប្រឈមចំពោះការប្រើប្រាស់នីតិវិធីដេញថ្លៃ។ ទោះជាយ៉ាងនេះក្តីបញ្ហាប្រឈមទាំងនេះ និងបញ្ហាប្រឈមស្មុគស្មាញផ្សេងទៀតត្រូវបានដោះស្រាយជាបណ្តើរៗតាមរយៈការដាក់ចេញនូវវិធានការជាក់លាក់ និងក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេសនឹងត្រូវដោះស្រាយតាមរយៈវិធានការបន្ថែមដែលបានដាក់ចេញក្នុងវិបស្សនានេះតែម្តង។

*ការអនុវត្តចំណាយថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានបង្កើនជាប្រចាំឆ្នាំស្របតាមទិសដៅវិមជ្ឈការ និងវិសហមជ្ឈការ។*

*ទន្ទឹមនេះ, កសហវ. បាននិងកំពុងគិតគូរកំណត់អត្រាវិភាជន៍បន្ថែមសម្រាប់មូលនិធិក្រុងស្រុកនិងមូលនិធិឃុំសង្កាត់ឆ្លើយតបនឹងនិន្នាការនៃការផ្ទេរមុខងាររបស់ក្រសួង-ស្ថាប័ន ជាបណ្តើរៗទៅរដ្ឋបាលក្រុង ស្រុក និងគោលដៅចំណាយអភិវឌ្ឍន៍មូលដ្ឋានជាមធ្យមសម្រាប់ឃុំ សង្កាត់ នីមួយៗ។*

ជាមួយគ្នានេះកសហវ. បាននិងកំពុងសិក្សាអំពីប្រភពចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដើម្បីផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសសម្រាប់រដ្ឋបាលក្រុងស្រុកនិងឃុំសង្កាត់ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។ ក្នុងដំណើរការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការយល់ដឹងអំពីនីតិវិធីអនុវត្តថវិកា, ការអនុវត្តកិច្ចលទ្ធកម្មនៅរដ្ឋបាលឃុំសង្កាត់, ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិ, និងការដេញថ្លៃខាងផ្នែកលទ្ធកម្មក៏នៅមានបញ្ហាប្រឈមផងដែរ។ ទោះជាយ៉ាងណាក៏ដោយបញ្ហាប្រឈមទាំងនេះត្រូវបានបន្តយកចិត្តដាក់ដោយថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទកសហវ. តាមរយៈការដាក់ចេញនូវវិធានការនានាហើយបច្ចុប្បន្នបញ្ហាប្រឈមទាំងនេះត្រូវបានកែលម្អជាបណ្តើរៗហើយនឹងបន្តមានភាពប្រសើរឡើងថែមទៀតតាមរយៈវិធានការបន្ថែមដែលបានដាក់ចេញក្នុងវិបស្សនានេះតែម្តង។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ណែនាំដល់ថ្នាក់ដឹកនាំនិងមន្ត្រីបច្ចេកទេសនៅគ្រប់អង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរសហវ. រាជធានី-ខេត្តឱ្យបន្តកិច្ចសហការល្អទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ជាប្រព័ន្ធ ព្រមទាំងយកស្មារតីនៃកិច្ចពិភាក្សានិងវិធានការបន្ថែមដាក់បានដាក់ចេញក្នុងវិបស្សនានេះទៅពង្រឹងកិច្ចការពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអនុវត្តថវិកាទាំងនៅរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិហើយផ្សារភ្ជាប់គ្នារវាងការងារប្រចាំថ្ងៃនិងការងារកែទម្រង់។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះគ្រប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃ កសហវ. ចំពោះការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងសម្រេចបានការងារនាពេលកន្លងមក ព្រមទាំងជូនពរគ្រប់ថ្នាក់ដឹកនាំមន្ត្រីរាជការទាំងអស់ ជួបប្រទះតែនឹងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃនៃ អ.គ.ហ.*

# កិច្ចពិគ្រោះយោបល់ស្តីពីការស្ទាបស្ទង់ទីផ្សារអំពីតម្រូវការមូលបត្ររដ្ឋ

*កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំ "កិច្ចពិគ្រោះយោបល់ស្តីពីការស្ទាបស្ទង់ទីផ្សារអំពីតម្រូវការមូលបត្ររដ្ឋ" ដោយមានកិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជា និងនិយ័តករមូលបត្រកម្ពុជា។*

កិច្ចពិគ្រោះយោបល់នេះមានការចូលរួមពីនិយ័តករពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងក្រុមលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ និងដោយមានការអញ្ជើញចូលរួមយ៉ាងច្រើនកុះករពីសំណាក់វិនិយោគិនស្ថាប័នសក្តានុពលរួមមាន÷ គ្រឹះស្ថានធនាគារពាណិជ្ជ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ, ក្រុមហ៊ុនធានារ៉ាប់រង, និងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ព្រមទាំងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ (រួមមាន÷ ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, លេខាធិការដ្ឋានអាស៊ាន, និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ) ផងដែរ។



កិច្ចពិគ្រោះយោបល់នេះមានគោលបំណងជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ និងដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ចំពោះមុខក្នុងការបោះផ្សាយមូលបត្ររដ្ឋ។ កន្លងមករាជរដ្ឋាភិបាលបានអនុម័តនិងដាក់ឱ្យអនុវត្ត "ក្របខណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ" កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១។

*ក្របខណ្ឌគោលនយោបាយបឋមនេះបានដាក់ចេញនូវវិធានការគោលនយោបាយ និងផែនការសកម្មភាពជាក់លាក់ដើម្បីអនុវត្តជំហាននៃការបោះផ្សាយមូលបត្ររដ្ឋ ជាពិសេសផែនការសកម្មភាពបន្ទាន់ចំពោះមុខនិងរយៈពេលខ្លីសំដៅឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋក្នុងទីផ្សារជាលើកដំបូងបាននៅឆ្នាំ២០២២។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏កំពុងបន្តរៀបចំផងដែរនូវ "ក្របខណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ" សំដៅកសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ។*

ជាវឌ្ឍនភាពជាក់ស្តែង, រាជរដ្ឋាភិបាលបានសម្រេចនូវកិច្ចការអាទិភាពចាំបាច់មួយចំនួនរួចហើយក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងស្របតាមពិដានដែលកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ក្នុងរង្វង់ ១,២ទ្រីលានរៀល (សមមូលនឹងប្រមាណ ៣០០លានដុល្លារអាមេរិក) មានជាអាទិ៍÷

ទី១) **ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត** សំខាន់ៗជាច្រើន ដូចជា÷ ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្ររដ្ឋដែលមានការចាត់តាំងធនាគារជាតិនៃកម្ពុជាជាអាណត្តិគាហកនិងកំណត់អំពីកិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋ, អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្ររដ្ឋ, និងសារាចរណែនាំស្តីពីការអនុវត្តចំពោះមូលបត្ររដ្ឋដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ក្រៅពីនេះក៏នៅមានលិខិតបទដ្ឋានគតិយុត្តអាទិភាពមួយចំនួនទៀតដែលកំពុងបន្តរៀបចំបញ្ចប់ហើយនឹងដាក់ឱ្យអនុវត្តឆាប់ៗនេះដែរដូចជា÷ ប្រកាសស្តីពីការប្រើប្រាស់មូលបត្ររដ្ឋក្នុងប្រតិបត្តិការរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា, ប្រកាសស្តីពីបែបបទនិងនីតិវិធីលម្អិតពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្ររដ្ឋ (SOP), និងប្រកាសស្តីពីការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុកហើយនឹងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្ររដ្ឋជាដើម។



ទី២) **ការពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្សតាមរយៈការបង្កើត**ជាការិយាល័យថ្មីមួយដែលមានឈ្មោះថា "ការិយាល័យមូលបត្ររដ្ឋ" ចំណុះឱ្យនាយកដ្ឋានគ្រប់គ្រងបំណុល នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញតួនាទីជាអង្គភាពសម្របសម្រួលរាល់កិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋនិងការអនុវត្តតាមអភិក្រម "រៀនបណ្តើរធ្វើបណ្តើរ។

ទី៣) **ការកំណត់ចរិតលក្ខណៈនៃមូលបត្ររដ្ឋនិងការរៀបចំបោះផ្សាយលក់មូលបត្ររដ្ឋ**, និង

ទី៤) **ការរៀបចំសេចក្តីព្រាងផែនការបោះផ្សាយលក់មូលបត្ររដ្ឋឆ្នាំ២០២២។**

ក្នុងការរៀបចំសេចក្តីព្រាងផែនការបោះផ្សាយលក់មូលបត្ររដ្ឋ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្លាប់បានរៀបចំកិច្ចពិគ្រោះយោបល់ស្តីពីការស្ទាបស្ទង់ទីផ្សារអំពីតម្រូវការមូលបត្ររដ្ឋ (Market Sounding) ចំនួន២ លើករួចមកហើយ តាមរយៈកិច្ចសម្ភាសន៍ពីចម្ងាយជាមួយវិនិយោគិនសក្តានុពលមួយចំនួន ដោយហេតុថានាពេលនោះ យើងកំពុងស្ថិតនៅក្នុងស្ថានភាពនៃការចូលរួមអនុវត្តវិធានការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងនោះ÷ **លើកទី១.** ធ្វើឡើងក្នុង ខែកញ្ញា ឆ្នាំ២០២១ ដោយមានការចូលរួមពីបណ្តាធនាគារពាណិជ្ជ, ក្រុមហ៊ុនធានារ៉ាប់រង, និង ប.ស.ស. (ក្រោមការដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងសម្របសម្រួលដោយធនាគារជាតិនៃកម្ពុជា)។

កិច្ចពិគ្រោះយោបល់លើកនេះ គឺជាការស្ទាបស្ទង់ទីផ្សារលើកទី៣ ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលធាតុចូលបន្ថែមទៀតឱ្យបានកាន់តែពេញលេញនិងគ្រប់ជ្រុងជ្រោយសម្រាប់ជាមូលដ្ឋានដ៏សំខាន់ក្នុងការពិនិត្យឡើងវិញ និងកែសម្រួលបន្ថែមលើសេចក្តីព្រាងផែនការបោះផ្សាយលក់មូលបត្ររដ្ឋឆ្នាំ២០២២ ដើម្បីស្នើសុំការពិនិត្យនិងអនុម័តដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។




កិច្ចពិគ្រោះយោបល់នេះបានបញ្ចប់ទៅប្រកបដោយផ្លែផ្កា ដោយមានសំណួរសំខាន់ៗជាច្រើនត្រូវបានលើកឡើងពីសំណាក់វិនិយោគិនគោលដៅក្នុងវិស័យមូលបត្ររដ្ឋ៕

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកានៃ អ.គ.ហ.*

# សិក្ខាសាលាស្ដីពីបទពិសោធនៃការអនុវត្តថវិកាកម្មវិធីថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

*ការស្ដាបស្ទង់កាលពីថ្ងៃទី០៦ ខែមករា និងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.), ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំសិក្ខាសាលាស្ដីពីបទពិសោធនៃការអនុវត្តថវិកាកម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតំណាងដ៏ឧត្តុង្គឧត្តមរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។*



សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធីនៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងផ្តល់ឱកាសឱ្យគ្រប់តួអង្គក្នុងការដកស្រង់បទពិសោធជាពុទ្ធិ និងមេរៀន ព្រមទាំងភាពជោគជ័យ, បញ្ហាប្រឈមនានានៃការអនុវត្តថវិកាកម្មវិធីគ្រប់ទិដ្ឋភាពនៃវដ្តថវិកា (ការរៀបចំ, ការអនុវត្ត, ការតាមដាននិងវាយតម្លៃ),ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនិងយន្តការស្ថាប័ន។ សិក្ខាសាលានេះត្រូវបានរៀបចំជា២វគ្គដែល **វគ្គទី១.** សម្រាប់ក្រសួង-ស្ថាប័នដោយអញ្ជើញចូលរួមជាវាគ្មិនពីតំណាងកសហវ., ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងបរិស្ថាន និងក្រសួងសុខាភិបាលដែលមានសិក្ខាកាមចូលរួមសរុបប្រមាណ ៦០០នាក់។ **វគ្គទី២.** សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដោយអញ្ជើញចូលរួមជាវាគ្មិនពីតំណាង កសហវ., រដ្ឋបាលរាជធានីភ្នំពេញ, រដ្ឋបាលខេត្តសៀមរាប, និងរដ្ឋបាលខេត្តព្រះសីហនុដែលសិក្ខាកាមចូលរួមសរុបប្រមាណ ១៥០០នាក់។








ជាសារវតារ ការអនុវត្តថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តសាកល្បងពេញលេញគ្រប់ក្រសួង-ស្ថាប័ន ចាប់ពីឆ្នាំ២០១៥-២០១៨និងគ្រប់រដ្ឋបាលរាជធានីខេត្តចាប់ពីឆ្នាំ២០១៧-២០២១។ នៅឆ្នាំ២០២១ អង្គភាពថវិកាមានចំនួនសរុប ៩២៦ ដែលក្នុងនោះរដ្ឋបាលថ្នាក់កណ្តាលមានចំនួន ៣២៣ និងថ្នាក់-មូលដ្ឋាន (មន្ទីរជំនាញរាជធានីខេត្ត) ចំនួន៦០៣។ សម្រាប់ថ្នាក់កណ្តាលអង្គភាពថវិកាចំនួន ៣២៣ ក្នុងនោះអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៨៣ និងមិនទាន់ផ្ទេរសិទ្ធិ ២៤០ និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន៦៨៦។

ឯកឧត្តម **រស់ សីលវ៉ា** បានគូសបញ្ជាក់ថា *រាជរដ្ឋាភិបាលបានចាត់ទុក "ថវិកា គឺជាឧបករណ៍គោលនយោបាយ" ដើម្បីគាំទ្រការអនុវត្តរបៀបវារៈគោល-នយោបាយរបស់រាជរដ្ឋាភិបាលឱ្យសម្រេចបានជោគជ័យនិងចីរភាព។* ជាក់ស្តែង, ទាំងផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធីគឺបានក្លាយជាឧបករណ៍មួយដ៏សំខាន់ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយដែលមានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងផែនការយុទ្ធសាស្ត្រតាមវិស័យ។ ក្នុងន័យនេះប្រសិនបើយើងមានគោលនយោបាយថវិកាត្រឹមត្រូវច្បាស់លាស់ គឺយើងនឹងអាចអនុវត្តគោលនយោបាយប្រកបដោយជោគជ័យនិងសម្រេចបាននូវបំណងប្រាថ្នាដែលយើងរំពឹងចង់បានហើយផ្ទុយទៅវិញបើយើងគ្មានគោលនយោបាយថវិកាច្បាស់លាស់ទេនោះថវិកាទាំងអស់ច្បាស់ជានឹងត្រូវបានប្រើប្រាស់ដោយខ្ជះខ្ជាយឥតប្រយោជន៍ជាមិនខាន។ កសហវ. បានយកចិត្តទុកដាក់លើការកែលម្អនូវគោលការណ៍ណែនាំស្តីពីនីតិវិធីរៀបចំ និងអនុវត្តថវិកាកម្មវិធី, ក្នុងគោលដៅពង្រឹងការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធីក្នុងគោលដៅធ្វើឱ្យប្រព័ន្ធថវិកាកាន់តែក្លាយទៅជាឧបករណ៍គោលនយោបាយយ៉ាងពិតប្រាកដក្នុងការវិភាជនិងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ឯកឧត្តម **រស់ សីលវ៉ា** បានផ្តល់អនុសាសន៍ជូនអង្គសិក្ខាសាលា ដើម្បីតម្រង់ទិសការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យសម្រេចបានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពដូចតទៅ÷

- **ចំពោះថ្នាក់ជាតិ**

**ទី១.** ពង្រឹងគុណភាពផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធីក្របខណ្ឌសមិទ្ធកម្មដោយកំណត់ចំនួនសូចនាករសមិទ្ធកម្ម, បញ្ជាក់ពីលទ្ធផលមូលដ្ឋាន, វិធីសាស្ត្រគណនា, មធ្យោបាយសម្រាប់ផ្ទៀងផ្ទាត់ និងគោលដៅ។

**ទី២.** កសហវ. និងក្រសួង ស្ថាប័នសាមីត្រូវសហការកំណត់ និងជំរុញអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកា។

**ទី៣.** គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការរៀបចំ និងបង្កើតអង្គភាពថវិកា(ការត្រួតពិនិត្យ និងរៀបចំលក្ខណៈសម្បត្តិកែសម្រួលរចនាសម្ព័ន្ធ ស្ថាប័ន និងការកសាងសមត្ថភាព)។

**ទី៤.** ពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដោយការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀតតាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្តដែលក្នុងនោះថ្នាក់ដឹកនាំ ឬថ្នាក់គ្រប់គ្រង ទទួលខុសត្រូវចំពោះសមិទ្ធកម្ម ឬការត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត។ ចំណែកការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៃក្រសួង-ស្ថាប័ន។

**ទី៥.** ជំរុញការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន។



ទី៦. ជំរុញការរៀបចំវេទិកាសាធារណៈស្តីពីថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នសាមីដើម្បីបង្កើនតម្លាភាពថវិកា និងការចូលរួមពីសាធារណជន។

• **ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ទី១.** ត្រៀមលក្ខណៈឱ្យបានរួចរាល់សម្រាប់ការកែទម្រង់ថ្មីៗ ស្របតាមទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកានៅរដ្ឋបាលថ្នាក់-ក្រោមជាតិជាពិសេសការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្ត និងការតម្រឹមផែនការជាមួយមន្ទីរជំនាញជុំវិញរដ្ឋបាលរាជធានី ខេត្ត។

**ទី២.** ពង្រឹងគុណភាពផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធីទាំងខ្លឹមសារនិងរចនាសម្ព័ន្ធកម្មវិធីព្រមទាំងការកំណត់នូវលទ្ធផលក្នុងឆ្នាំនិងលទ្ធផលចុងក្រោយប្រកបដោយភាពច្បាស់លាស់និងប្រាកដនិយម។

**ទី៣.** ពិនិត្យលទ្ធភាពបង្កើនចំនួនអង្គ-ភាពថវិកានិងការប្រគល់សិទ្ធិអំណាចទៅឱ្យអង្គភាពថវិកា នៅតាមរដ្ឋបាលរាជធានីខេត្តសាមីដើម្បីឱ្យស្របទៅនឹងទិសដៅនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ទី៤.** ពង្រឹងយន្តការស្ថាប័ន និងកិច្ច-សហការគ្រប់តួអង្គពាក់ព័ន្ធជាពិសេសលើតួនាទីនិងភារកិច្ចរបស់គណៈកម្មការសម្របសម្រួលបច្ចេកទេស, ក្រុមការងារថវិការបស់រដ្ឋបាលរាជធានីខេត្ត, អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ, មន្ត្រីបច្ចេកទេសរបស់កសហវ. ជាដើមនិងការត្រួតពិនិត្យតាមដានការអនុវត្តថវិកាកម្មវិធី ប្រចាំឆមាស និងឆ្នាំផ្សារភ្ជាប់ជាមួយថវិកា។

**ទី៥.** បង្កើនការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងការអនុវត្តថវិកាកម្មវិធីសំដៅឱ្យកម្រិតនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយកាន់តែមានភាពប្រសើរឡើង។

**ទី៦.** ពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដោយការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀតតាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្តដែលក្នុងនោះថ្នាក់ដឹកនាំឬថ្នាក់-គ្រប់គ្រងទទួលខុសត្រូវចំពោះសមិទ្ធកម្មឬការត្រួតពិនិត្យ លើលទ្ធផលនៃការអនុវត្ត។ចំណែកការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចនៃរដ្ឋបាលរាជធានី ខេត្ត។

**ទី៧.** ជំរុញការរៀបចំវេទិកាសាធារណៈស្តីពីថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានីខេត្ត ដើម្បីបង្កើនតម្លាភាពថវិកា និងការចូលរួមពីសាធារណជន។

ជារួម, ការរៀបចំសិក្ខាសាលាស្តីពីបទពិសោធនៃការអនុវត្តថវិកាកម្មវិធីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនេះគឺសម្រេចបានតាមលទ្ធផលរំពឹងទុកដោយបានបញ្ជាបការកែទម្រង់លើសមាសធាតុគន្លឹះៗនៃការអនុវត្តថវិកាកម្មវិធី ដែលរួមមាន ÷ (ទី១). បង្កើនការយល់ដឹងនិងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាប្រចាំឆ្នាំ ដោយផ្សារភ្ជាប់ជាមួយគោលនយោបាយដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងយុទ្ធសាស្ត្រតាមវិស័យព្រមទាំងវិធីសាស្ត្រកំណត់លទ្ធផលក្នុងឆ្នាំ(Outputs) និងលទ្ធផលចុងក្រោយ (Outcomes) ឱ្យមានភាពច្បាស់លាស់និងប្រាកដនិយម, (ទី២). ទទួលបាននូវបទពិសោធក្នុងការពង្រឹងយន្តការស្ថាប័ន តាមរយៈការបង្កើនការសម្របសម្រួលរវាងអង្គភាពហិរញ្ញវត្ថុនិងអង្គភាពថវិកា និងយន្តការត្រួតពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តថវិកាកម្មវិធីនិង(ទី៣). ទទួលបាននូវបទពិសោធក្នុងការធ្វើវិមជ្ឈការហិរញ្ញវត្ថុផ្ទៃក្នុងក្រសួងស្ថាប័នតាមរយៈការបង្កើតអង្គភាពថវិកានិងការបង្កើនសិទ្ធិអំណាចទៅឱ្យអង្គភាពថវិកា៕

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃនៃ អ.គ.ហ.*












# ផ្នែកទី ២

# អត្ថបទ

# អាទិភាពនិងក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣-២០២៧

*ស្របតាមអភិក្រមជាខឿន (platform approach) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដ្យាក្រាមទី១), ផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣-២០២៧ ត្រូវផ្តល់អាទិភាពខ្ពស់លើការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការរៀបចំនិងការអភិវឌ្ឍប្រព័ន្ធក្របខណ្ឌគតិយុត្ត យន្តការ និងធនធានមនុស្ស ដើម្បីកែលម្អដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យអាចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងអាចគាំទ្រដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។*

*ដ្យាក្រាមទី១÷ អភិក្រមនៃកម្មវិធីកែទម្រង់ PFM*




ពិតណាស់,ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនមែនទាល់តែប្រព័ន្ធនោះមាននូវមុខងារគ្រប់ទាំងអស់នោះទេ។ និយាយម្យ៉ាងវិញទៀតមានន័យថាការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយប្រកបដោយប្រសិទ្ធភាព ត្រូវផ្តល់អាទិភាពលើមុខងារចាំបាច់ ដែលនឹងត្រូវប្រើប្រាស់។ ក្នុងន័យនេះ, ខ្លឹមសារសំខាន់នៃសេចក្តីព្រាងបឋមនេះគឺផ្តោតលើការបង្កើតបរិយាកាសអំណោយផលសម្រាប់អនុវត្តសកម្មភាពកែទម្រង់និងតម្រឹមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានសង្គតិភាពទៅនឹងគោលការណ៍វិធាននិងនីតិវិធីនៃការរៀបចំនិងអនុវត្តថវិកាព័តិមានសមិទ្ធកម្ម( ដ្យាក្រាមទី២)។

សេចក្តីព្រាងបឋម CAP4 ត្រូវបានរក្សាទម្រង់បែងចែកជា៥ផ្នែកហើយជាក្របខណ្ឌលទ្ធផល, សេចក្តីព្រាងនេះនឹងពង្រឹងមុខងារ និងសមត្ថភាពនៃប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានភាពសម្បូរបែប (sophisticated) និងមានភាពធន (resilient) ដែលអាចធានានូវនិរន្តរភាពនៃចលនការការងារកែទម្រង់, ទ្រទ្រង់នូវប្រតិបត្តិការគ្រប់គ្រងចំណូលចំណាយសាធារណៈស្របតាមទិសដៅយុទ្ធសាស្ត្ររបស់ប្រមុខរាជរដ្ឋាភិបាល, និងបញ្ជ្រាបវប្បធម៌សមិទ្ធកម្មដល់គ្រប់អង្គភាពសាធារណៈឱ្យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពជាម្ចាស់, មានវិន័យ និងគណនេយ្យភាព ព្រមទាំងអាចធ្វើឱ្យប្រសើរឡើងនូវលទ្ធផលហិរញ្ញវត្ថុ (fiscal outcomes)។ សេចក្តីព្រាងបឋមCAP4 ត្រូវបានរៀបចំដោយផ្តោតលើអាទិភាពនិងខ្លឹមសារដូចខាងក្រោម÷





*ដ្យាក្រាមទី២÷ ក្របខណ្ឌលទ្ធផល CAP4*







## *ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា*

នឹងបន្តពង្រឹងការដ្ឋានកែទម្រង់ដែលមានស្រាប់ រួមមានការធ្វើពិពិធកម្មចំណូលដោយចាប់ផ្តើមអនុវត្តពន្ធលើប្រាក់ចំណេញ Capital Gain Tax និងពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល Personal Income Tax, ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារនិងការបង្កើនប្រសិទ្ធភាពនៃការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធបន្ថែម។ ទន្ទឹមនេះ, ផ្នែកនេះក៏នឹងពង្រឹងការអនុវត្តថវិកាដោយពង្រឹងការរៀបចំផែនការចំណាយការវិភាជន៍ថវិកាជូន អង្គភាពថវិកាការពន្លឿននីតិវិធីលទ្ធកម្មសាធារណៈ និងការប្រើប្រាស់ឥណទាន រជ្ជទេយ្យបុរេប្រទាន។




## *ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ*

នឹងបន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ឱ្យក្លាយជាឆ្អឹងខ្នងឧបករណ៍ស្នូលក្នុងការធ្វើស្វ័យប្រវត្តិកម្មការរៀបចំ និងអនុវត្តថវិកានិងផលិតរបាយការណ៍ដែលអនុលោមទៅនឹងស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ។ ម្យ៉ាងទៀត, ផ្នែកនេះក៏គិតគូរពង្រីកវិសាលភាពគ្របដណ្តប់នៃគណនីទោលរបស់ជាតិក្នុងការកត់ត្រានិងរាយការណ៍ហិរញ្ញប្បទានពីក្រៅប្រទេស (សម្រាប់តាមដានហានិភ័យបំណុល), ប្រតិបត្តិការហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ, និងស្ថិតិទិន្នន័យនៃទ្រព្យសម្បត្តិរដ្ឋផងដែរ។




## *ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅគោលនយោបាយ*

នឹងផ្តល់អាទិភាពលើការពង្រឹងការរៀបចំ និងការអនុវត្តផែនការថវិកាប្រចាំឆ្នាំនិងរយៈពេលមធ្យម ដោយកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាBSP និងផែនការអនុម័តលើក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម MTFF និងក្របខណ្ឌថវិការយៈពេលមធ្យម MTBF។ ទន្ទឹមនេះសេចក្តីព្រាងបឋមផ្នែកនេះ ក៏នឹងពន្លឿនការកែសម្រួលនិងរៀបចំបញ្ចប់នូវលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីប្រតិបត្តិរួមសម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ។ បន្ថែមពីនេះ, ផ្នែកនេះនឹងជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ដោយផ្តោតលើការធ្វើសមាហរណកម្មផែនការថវិកា, ការធ្វើប្រតិភូកម្មសិទ្ធិអំណាច, ការផ្ទេរធនធានសម្រាប់អនុវត្តមុខងារផ្ទេរទៅថ្នាក់ក្រោមជាតិ, ការរៀបចំនិងពង្រឹងយន្តការគ្រប់គ្រងវិនិយោគសាធារណៈ, និងការពង្រឹងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ។




*ផ្នែកទី៤÷ ការកសាងគណនេយ្យភាពសមិទ្ធកម្ម* នឹងផ្តោតលើការបណ្តុះវប្បធម៌សមិទ្ធកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកលើមូលដ្ឋានច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ដែលគ្រោងនឹងទទួលបានការអនុម័តក្នុងឆ្នាំ ២០២២, សេចក្តីព្រាងបឋមCAP4 ឆ្នាំ ២០២៣-២០២៧នឹងជំរុញការដាក់ឱ្យអនុវត្តក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម និងប្រព័ន្ធតាមដាន និងវាយតម្លៃសមិទ្ធកម្មតាមក្រសួង-ស្ថាប័ន។ សកម្មភាពកែទម្រង់សំខាន់ៗក្នុងផ្នែកនេះរួមមានការដាក់ឱ្យដំណើរការក្រុមអភិបាលថវិកា, កិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ, ការពង្រឹងយន្តការតាមដាននិងវាយតម្លៃសមិទ្ធកម្មនិងមុខងារសវនកម្មសមិទ្ធកម្ម។ បន្ថែមពីនេះអាទិភាពក៏បន្តផ្តោតលើការរៀបចំវេទិកាសាធារណៈនិងផ្សព្វផ្សាយឯកសារថវិកាដើម្បីលើកកម្ពស់តម្លាភាពថវិកា ឱ្យស្របតាមឧត្តមានុវត្តន៍ក្នុងក្របខណ្ឌវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ PEFA។



*ផ្នែកទី៥÷ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត* នឹងបន្តពង្រឹងសមត្ថភាពនិងភាពជាអ្នកដឹកនាំរបស់អង្គភាពអនុវត្តការងារកែ-ទម្រង់ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់។ ផ្នែកនេះក៏នឹងជំរុញការរៀបចំបញ្ចប់នូវមូលនិធិគ្រប់ជ្រុងជ្រោយ, គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (RBM-PFMRP) និងការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មាន សមិទ្ធកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PMAS)។

បន្ថែមពីនេះ, ទិសដៅសកម្មភាពនៃកម្មវិធីកែទម្រង់ទាំងពាក់ត្រូវសម្របសម្រួលតម្រឹមបន្ថែមដើម្បីកំណត់គុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងរៀបចំឯកសារបទដ្ឋានគតិយុត្តិនិងគោលការណ៍សម្រាប់ ជ្រើសរើស/តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយផ្អែកលើការវាយតម្លៃនិងចាត់តាំងលក្ខខណ្ឌយោងការងារច្បាស់លាស់។

សេចក្តីព្រាងបឋម CAP4 នឹងត្រូវតាក់តែងឱ្យមានសូចនាករសមិទ្ធកម្មគោលដៅប្រចាំឆ្នាំនិងវិធីសាស្ត្រវាស់វែងច្បាស់លាស់រួចទើបរៀបចំពិនិត្យនិងពិគ្រោះយោបល់រួមគ្នាជាមួយតួអង្គពាក់ព័ន្ធនៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល, តំណាងដៃគូអភិវឌ្ឍន៍។ សេចក្តីព្រាងចុងក្រោយ CAP4 នឹងត្រូវគោរពស្នើសុំគោលការណ៍ឯកភាព(endorsement)ពីគណៈកម្មា-ធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងត្រីមាសទី៣ ឆ្នាំ២០២២៕

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធនៃ អ.គ.ហ.*

*ដ្យាក្រាមទី៣÷ ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*








# ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្តីពីការរៀបចំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងបរិបទឌីជីថលនីយកម្មនៅកម្ពុជា

*គេហទំព័រមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលទីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមគណៈអធិបតីដ៏ខ្ពស់ខ្ពស់ ឯកឧត្តម **វង្ស វិសុទ្ធ** រដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) គឺជាសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ក្នុងការដឹកនាំរៀបចំសម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលព្រមទាំងការសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។*

ស្របតាមផែនការសកម្មភាពលម្អិតឆ្នាំ២០២១របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** កាលទីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ លើការរៀបចំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ដើម្បីជាឧបករណ៍សម្រាប់លើកកម្ពស់និងតម្លាភាពហិរញ្ញវត្ថុសាធារណៈក៏ដូចជាឧបករណ៍ផ្សព្វផ្សាយពីព័ត៌មានសេដ្ឋកិច្ចរបស់រាជធានី-ខេត្តដើម្បីមានជាមូលដ្ឋានក្នុងការបោះជំហានឆ្ពោះទៅកាន់រដ្ឋបាលតាមប្រព័ន្ធអេឡិចត្រូនិចនិងសេដ្ឋកិច្ចឌីជីថលដើម្បីពង្រឹងសមត្ថភាពរៀបចំវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការវិភាគ SWOT។



គេហទំព័រមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តត្រូវបានរៀបចំនិងអភិវឌ្ឍក្នុងគោលបំណងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ព័ត៌មានការអនុវត្តថវិកានិងការរៀបចំថវិកានៅថ្នាក់ក្រោមជាតិដើម្បីគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដូច្នេះព័ត៌មានស្តីពីការគ្រប់គ្រងនិងការអនុវត្តថវិកាបានចូលរួមចំណែកក្នុងការលើកកម្ពស់តម្លាភាពថវិកានិងគណនេយ្យភាពហិរញ្ញវត្ថុជូនសាធា-រណៈជននិងមន្ត្រីរាជការ។ទន្ទឹមនឹងនេះព័ត៌មានសេដ្ឋកិច្ចនិងសង្គមក៏បានផ្តល់ជាព័ត៌មានសម្រាប់ការវិនិយោគ និងផ្តល់ទិន្នន័យជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តរបស់អ្នកវិនិយោគតាមបណ្តារាជធានី-ខេត្តនៅទូទាំងប្រទេសហើយវានឹងចូលរួមលើកកម្ពស់ចំណូលសារពើ-ពន្ធសម្រាប់ហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ក្រោមជាតិផងដែរ។

ជាមួយគ្នានេះក្រុមការងារនៃអ.គ.ហ. ក៏ធ្លាប់បានរៀបចំសិក្ខាសាលាបណ្តុះ-



បណ្ដាលខ្លីក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរួចហើយដែរដើម្បីបញ្ជ្រៀបពីការយល់ដឹងលើការអភិវឌ្ឍសេដ្ឋកិច្ច។ក្នុងឆ្នាំ២០២២ នេះ អ.គ.ហ. គ្រោងនឹងរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលបន្ថែមទៀតដើម្បីចែករំលែកជាចំណេះដឹងជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត។ ក្នុងត្រីមាសទី១ ឆ្នាំ២០២២ អ.គ.ហ. ក៏ធ្លាប់បានរៀបចំសិក្ខាសាលានៃការវិភាគ SWOT ២ដង រួចមកហើយជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត។ ទោះបីជាយ៉ាងនេះមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវការអនុវត្តនិងសិក្សាស្វែងយល់ឱ្យច្បាស់បន្ថែមលើការរៀបចំ SWOT ដូចនេះ នាពេលខាងមុខ អ.គ.ហ. និងរៀបចំកិច្ចប្រជុំជាថ្មីម្ដងទៀតដើម្បីពិនិត្យនិងកែតម្រូវលើរបាយការណ៍ និងពន្យល់លម្អិតបន្ថែមលើការងារនេះដើម្បីត្រៀមដាក់បញ្ចូលទៅក្នុងគេហទំព័រ។

ទន្ទឹមនឹងនេះ អ.គ.ហ. បានរៀបចំកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអគ្គនាយកដ្ឋានគោលនយោបាយនៃកសហវ., មន្ទីរផែនការរាជធានី-ខេត្ត, និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ដើម្បីផ្ដល់ទិន្នន័យឱ្យគ្រប់ជ្រុងជ្រោយក្នុងការដាក់បញ្ចូលទិន្នន័យទៅក្នុងគេហទំព័រ ដើម្បីផ្ដល់ជូនព័ត៌មានសេដ្ឋកិច្ច និងសង្គមនិងព័ត៌មានជាច្រើនផ្សេងៗទៀតជូនសាធារណៈជនទាញយកទៅប្រើប្រាស់ស្របតាមតម្រូវការ។

ជារួម គេហទំព័រមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តនឹងផ្ដល់ជាអត្ថប្រយោជន៍ជាច្រើនជូនសាធារណជន ក៏ដូចជាការបង្ហាញអត្តសញ្ញាណរបស់មន្ទីរខេត្តជាសកលជូនជាសាធារណៈ ដើម្បីផ្ដល់ជាព័ត៌មានទូទៅអំពីព័ត៌មាន និងព្រឹត្តិការណ៍ប្រចាំរាជធានីខេត្តជូនជាសាធារណៈ, ផ្ដល់ព័ត៌មានស្ថានភាពស្ថិតិសេដ្ឋកិច្ចនិងសង្គម, ងាយស្រួលក្នុងការទាញយកឯកសារចម្រុះរបស់មន្ទីររាជធានី-ខេត្ត, ងាយស្រួលគ្រប់គ្រងឯកសារក្នុងដែនសមត្ថកិច្ចរបស់មន្ទីរ, ងាយស្រួលធ្វើការចែករំលែកព័ត៌មានទៅបណ្ដាញសង្គមនិងគ្រប់គ្រងទិន្នន័យតាមប្រភេទមាតិកាចម្រុះក្នុងគេហទំព័រនៅទូទាំងរាជធានី-ខេត្ត ស្របតាមផែនការរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃនៃ អ.គ.ហ.*








# ការត្រៀមដាក់ឱ្យដំណើរការប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១ ទៅកាន់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ

*ស្របតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងការដឹកនាំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ បានជំរុញក្រុមការងារ FMIS ឱ្យសហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធបន្តការសិក្សាលទ្ធភាពក្នុងការជ្រើសរើសខេត្តចំនួន០៥និងស្រុកពីរឬបី សម្រាប់ការដាក់ឱ្យប្រើប្រាស់ជាជំហានដំបូង នូវប្រព័ន្ធឯកសារឌីជីថល(FMIS Portal) ជំនាន់ទី១។ បច្ចុប្បន្ន ក្រុមការងារ FMIS បានសម្រេចនូវការអភិវឌ្ឍប្រព័ន្ធឯកសារឌីជីថល (FMISPortal) ជំនាន់ទី១ដែលនឹងត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការដល់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។*

ប្រព័ន្ធឯកសារឌីជីថល(FMIS Portal) បង្កើតឡើងដើម្បីជួយសម្រួលដល់ការទំនាក់ទំនងនិងបញ្ជូនឯកសារបានទាន់ពេលវេលាពីរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ មកកាន់រតនាគាររាជធានី-ខេត្ត។ជាពិសេសជាងនេះទៅទៀតមន្ត្រីអនុវត្តថវិកានិងហិរញ្ញវត្ថុនៅតាមរដ្ឋបាលស្រុកនិងរដ្ឋបាលឃុំដែលធ្លាប់តែជួបប្រទះនូវផលវិបាកនៅក្នុងការបញ្ជូនឯកសារពីទីតាំងដែលមានចម្ងាយឆ្ងាយដែលបានបង្កភាពយឺតយ៉ាវកកស្ទះឯកសារនានានឹងទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ប្រព័ន្ធទំនើបកម្មនេះដោយការប្រើតាមរយៈទូរស័ព្ទវៃឆ្លាត Android និងទូរស័ព្ទវៃឆ្លាត ISO។




*ប្រព័ន្ធនេះនឹងជួយសម្រួលដល់ការបើកផ្ដល់និងបង្កើនប្រសិទ្ធភាពតម្លាភាពនិងគណនេយ្យភាពនៃការចំណាយរបស់រដ្ឋបាលស្រុក និងរដ្ឋ*

ក្នុងការស្នើសុំចំណាយបោះពុម្ពសាលាកបត្រនិងការផ្ទេរឥណទានផ្សេងៗ ត្រូវបានប្រគល់សិទ្ធិជូនរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ ដោយការប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី១។ ភាពចំណេញពេលវេលា និងការកាត់បន្ថយចំណាយផ្សេងៗក្នុងការធ្វើដំណើរនៃការបញ្ជូនឯកសារនឹងជួយជំរុញដល់ការបម្រើសេវាសាធារណៈនៅតាមរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ

ឱ្យកាន់តែល្អប្រសើរ និងជាការចូលរួមអនុវត្តនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

គួរបញ្ជាក់ផងដែរថា ក្រុមការងារ FMIS សហការជាមួយមន្ត្រីជំនាញនៃរតនាគាររាជធានី ខេត្តបានផ្តល់ការបណ្តុះបណ្តាលជូនមន្ត្រីនៃរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សរុបបានចំនួន ៧៥ ស្រុក និង ១៨៥ឃុំ ដែលបានធ្វើឡើងកាលពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២៕

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*











# ជំនាញការ IMF: ប្រព័ន្ធ FMIS គឺជាកាតាលីករដ៏សំខាន់បំផុតក្នុងការជំរុញល្បឿននៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យបាននៅដល់គោលដៅ និងការពង្រឹងការអនុវត្តច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនៅកម្ពុជា

*មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅតែប្រកាន់គោលជំហរក្នុងការគាំទ្រគម្រោង FMIS បន្តទៀតជាមួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដោយសារប្រព័ន្ធ FMIS គឺជាកាតាលីករមួយដ៏សំខាន់បំផុតក្នុងការជំរុញល្បឿននៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យបានទៅដល់គោលដៅ និងការពង្រឹងការអនុវត្តច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនៅកម្ពុជា។ នេះជាប្រសាសន៍របស់លោកស្រី **Delphine Moretti** ទីប្រឹក្សាផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំតំបន់អាស៊ីអាគ្នេយ៍នៅក្នុងជំនួបមួយជាមួយឯកឧត្តម **មន្ត ច្រាថ្លា** អគ្គលេខាធិការរង និងជាអនុប្រធានប្រចាំការក្រុមការងារគ្រប់គ្រងគម្រោង FMIS តំណាងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២។*

ជំនួបនេះមានគោលបំណងក្នុងការបញ្ជាក់អំពីពេលវេលាដ៏សមស្របក្នុងការបន្តកិច្ចសហការផ្តល់ជំនួយបច្ចេកទេសលើការវាយតម្លៃជាប្រចាំពីអ្នកជំនាញរបស់មូលនិធិរូបិយវត្ថុអន្តរជាតិលើការអនុវត្តគម្រោង FMIS ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលគ្រោងស្នើធ្វើឡើងជាថ្មីសម្រាប់ឆ្នាំ២០២២នេះនៅក្នុងកំឡុងខែវិច្ឆិកាឆ្នាំ២០២២អាស្រ័យលើការសម្រេចចុងក្រោយរបស់ថ្នាក់ដឹកនាំកំពូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កាលបរិច្ឆេទនេះគឺជាពេលវេលាដ៏សមស្របបំផុត ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញក្រោមឱវាទបានអនុវត្តនីតិវិធីអនុវត្តការងារ



គ្រប់មុខសញ្ញាទាំងស្រុងតាមប្រព័ន្ធFMIS ដោយគ្មាននីតិវិធីខាងក្រៅមានចំនួន១ត្រីមាសនិងការអនុវត្តមុខងាររបស់ប្រព័ន្ធថ្មីចំនួន២ គឺមុខងាររៀបចំផែនការថវិកានៅការដ្ឋានចំនួន១១ក្រសួង- ស្ថាប័នថ្មី និងមុខងារលទ្ធកម្មពេញលេញនៅគ្រប់ក្រសួង- ស្ថាប័នបានជិត២ត្រីមាស និងជាពេលវេលាដែលក្រសួង- ស្ថាប័ន និងអង្គភាពក្រោមឱវាទផុតពេលប្រញឹកខ្លាំងក្នុងការរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០២៣។ បន្ទាប់ពីបានស្តាប់អំពីការផ្តល់ព័ត៌មានស្តីពីវឌ្ឍនភាព, បញ្ហាប្រឈម,



ទិសដៅ និងការផ្លាស់ប្តូរយោបល់អំពីការអនុវត្តគម្រោង FMIS ពីឯកឧត្តម **មន្ត ច្រាថ្នា** រួចមក លោកស្រី Delphine Moretti បានបញ្ជាក់ថា ការអនុវត្តនីតិវិធីអនុវត្តការងារតាមប្រព័ន្ធFMIS មានចំនួន៣ដំណាក់កាលឬវិធីសាស្រ្តគឺ÷

**១-** ការធ្វើកុំព្យូទ័រភាវូបនីយកម្មនីតិវិធីអនុវត្តការងារទាំងស្រុងទៅក្នុងប្រព័ន្ធ (Computerize all processes),

**២-** ការកែសម្រួល និងតម្រង់ទិសនីតិវិធីអនុវត្តការងារ (All processes streamlining)

**៣-** ការធ្វើវិស្វកម្មឡើងវិញលើនីតិវិធីអនុវត្តការងារ(Processes reengineering) ដែលកម្ពុជាគួរជ្រើសរើសយកដំណាក់កាលឬវិធីសាស្រ្តណាមួយមកអនុវត្តក៏បាន សំខាន់គឺមិនត្រូវមានការអនុវត្តនីតិវិធីខាងក្រៅប្រព័ន្ធ FMIS បន្តទៅទៀត។

ឯកឧត្តម **មន្ត ច្រាថ្នា** បានបញ្ជាក់ថា កម្ពុជាបានជ្រើសរើសយកវិធីសាស្រ្តទាំង៣មកបូកបញ្ចូលគ្នាអនុវត្តតែម្តងពោលគឺព្យាយាមកាត់បន្ថយនូវការអនុវត្តនីតិវិធីដោយដៃដែលពុំមានតម្លៃបន្ថែមជាអតិបរមាដើម្បីដាក់អនុវត្តក្នុងប្រព័ន្ធ ហើយបច្ចុប្បន្ននេះបានឈានមកដល់ដំណាក់កាលកែសម្រួលនិងតម្រង់ទិសនីតិវិធីអនុវត្តការងារទាំងស្រុងមកអនុវត្តតែក្នុងប្រព័ន្ធ FMIS ហើយបន្ទាប់ពីបានអនុវត្តនីតិវិធីពាក់ព័ន្ធនឹងការទូទាត់ប្រាក់បៀវត្ស ទូទាត់ត្រង់ និងចំណាយមានគោលរបបច្បាស់លាស់ហើយនៅក្នុងពេលខាងមុខ ក្រសួងនឹងពិចារណាធ្វើការ វិស្វកម្មឡើងវិញលើមុខសញ្ញាចំណាយមួយចំនួនជាពិសេសគឺបុរេប្រទានដែលខាងមូលនិធិរូបិយវត្ថុអន្តរជាតិក៏ដូចជាដៃគូអភិវឌ្ឍន៍នានាយល់ថាមិនគួរបន្តឱ្យមាននូវចំណាយបុរេប្រទាននេះទៀតជាពិសេសនៅពេលដែលគ្រប់មុខសញ្ញាចំណាយទាំងអស់ត្រូវបានអនុវត្តតាមប្រព័ន្ធទាំងស្រុងហើយ ពុំគួរមានអ្វីជាឧបសគ្គក្នុងការរាំងស្ទះដល់ដំណើរការទូទាត់ថវិកាឱ្យបានលឿន និងទាន់ពេលវេលាឡើយ ហើយមុខសញ្ញានេះក៏មិនមានកម្រិតហានិភ័យខ្ពស់អ្វីទៀតទេ។ លោកស្រី Delphine Moretti បានបញ្ជាក់ថានឹងគាំទ្រការដោះស្រាយបញ្ហាចំណាយថវិកាជាតិតាមបុរេប្រទាននេះដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកា, ការបិទការិយបច្ឆេទថវិកានិងគណនេយ្យឱ្យបានទាន់ពេលវេលានិងការពង្រឹងការរៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុឱ្យបានកាន់តែប្រសើរឡើងជាមួយនឹងការជំរុញបញ្ចប់ការរៀបចំរបាយការណ៍ IPSAS និងការពិនិត្យលើលទ្ធភាពនៃការបង្កើនប្រសិទ្ធភាពនៃការព្យាករណ៍សាច់ប្រាក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ៕

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*





# លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ក្នុងកិច្ចការគ្រប់គ្រង និងការប្រមូលចំណូលពន្ធដារ

*ស្ថិតក្រោមបរិយាកាសនៃសុខសន្តិភាព និងស្ថិរភាពនយោបាយល្អប្រសើរ ជាមួយស្ថានភាពនៃម៉ាក្រូសេដ្ឋកិច្ចដែលមានលក្ខណៈល្អប្រសើរជាពិសេសស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងភាពឈ្លាសវៃរបស់* ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** *និងក្រោមកិច្ចគាំទ្រ ក៏ដូចជាការណែនាំចង្អុលបង្ហាញដោយផ្ទាល់ពីសំណាក់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ* ***អូន ព័ន្ធមុនីរ័ត្ន*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ ក្នុងនាមជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានឱកាស និងលទ្ធភាពគ្រប់គ្រាន់ ក្នុងការដាក់ចេញ និងអនុវត្តនូវកម្មវិធីកែទម្រង់គោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ តាមរយៈការធ្វើបច្ចុប្បន្នភាព និងធ្វើទំនើបកម្មនូវគ្រប់ផ្នែកទាំងអស់ រាប់ចាប់ពីការកែទម្រង់ និងកែលម្អរចនាសម្ព័ន្ធរដ្ឋបាល ធនធានមនុស្ស ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រហូតដល់មុខងារប្រតិបត្តិការស្នូលទាំងអស់ មានជាអាទិ៍ ការចុះបញ្ជីពន្ធដារ ការផ្តល់សេវាអ្នកជាប់ពន្ធ ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្ម ការប្រមូលបំណុលពន្ធ និងការដោះស្រាយបណ្តឹងតវ៉ា។*

ការងារកែទម្រង់មិនមែនគ្រាន់តែជាកិច្ចការដែលអាចជួយបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការអនុវត្តការងារប្រចាំថ្ងៃប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមាននិងបង្កើតកាលានុវត្តភាពថ្មីៗឆ្ពោះទៅរកការអភិវឌ្ឍនិងវិបុលភាពផងដែរ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារ បាននឹងកំពុងខិតខំយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាបានប្រសិទ្ធភាព ផលិតភាព តម្លាភាព សមភាពនិងគណនេយ្យភាពនូវនីតិវិធីនៃការគ្រប់គ្រងនិងប្រមូលចំណូលពន្ធ




| ប្រភេទពន្ធ | ត្រីមាសទី១ ឆ្នាំ ២០២២ | ត្រីមាសទី១ ឆ្នាំ ២០២១ | លម្អៀង | កំណើនធៀបគិតជា % |
|---|---|---|---|---|
| ពន្ធលើប្រាក់ចំណូល | 2,698.02 | 2,182.85 | 515.18 | 23.60% |
| អាករលើតម្លៃបន្ថែម | 774.02 | 672.22 | 101.80 | 15.14% |
| អាករពិសេស | 298.47 | 257.62 | 40.85 | 15.86% |
| ពន្ធលើប្រាក់បៀវត្ស | 315.00 | 259.95 | 55.05 | 21.18% |
| ពន្ធប្រថាប់ត្រា (ផ្ទេរអចលនទ្រព្យ) | 226.80 | 167.85 | 58.94 | 35.12% |
| ពន្ធឈ្នួលផ្ទះ និង ដី | 4.92 | 4.93 | (0.01) | -0.29% |

ឯកតា ៖ គិតជា ប៊ីលានរៀល




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | 2,360.05 | 3,036.32 | 3,604.89 | 4,267.99 | 5,210.00 | 6,010.48 | 7,906.52 | 8,791.66 | 11,277.32 | 11,700.52 | 11,266.79 | 5,115.42 |
| ចំណូល (លានដុល្លារ) | $590.01 | $759.08 | $901.22 | $1,067.00 | $1,302.00 | $1,502.62 | $1,976.64 | $2,197.85 | $2,819.33 | $2,889.02 | $2,781.92 | $1,263.07 |
| ផែនការ (ប៊ីលានរៀល) | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 | 9,084.42 | 11,419.13 |
| ផែនការ (លានដុល្លារ) | $663.84 | $736.11 | $865.90 | $993.79 | $1,164.88 | $1,421.56 | $1,715.83 | $1,923.38 | $2,288.41 | $2,850.20 | $2,243.07 | $2,819.54 |
| %ភាគរយនៃចំណូល | 88.88% | 103.12% | 104.08% | 107.40% | 111.82% | 105.70% | 115.20% | 114.27% | 123.20% | 101.36% | 124.02% | 44.80% |

1

ឱ្យបានគ្រប់ផែនការតាមរយៈការពង្រឹង និងចូលរួមអនុវត្តយ៉ាងសកម្ម នូវគោលនយោបាយកែទម្រង់ទាំងក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFM) និងទាំងក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (RMS)។

*លទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ស្តែងឱ្យឃើញតាមរយៈការកើនឡើងនូវចំណូលពន្ធផ្ទៃក្នុងជាប់ៗ គ្នាជារៀងរាល់ឆ្នាំ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។*

ជាក់ស្តែងសម្រាប់ត្រីមាសទី១ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារសម្រេចបានចំនួន **៥ ១១៥,៤២ប៊ីលានរៀល** (ប្រមាណជា **១ ២៦៣,០៧លានដុល្លារ**) ស្មើនឹង **៤៤,៨០%** នៃផែនការប្រចាំឆ្នាំ ដែលក្នុងនោះ សម្រាប់តែខែមីនានៃផែនការប្រចាំឆ្នាំដែលក្នុងនោះសម្រាប់តែខែមីនាមួយខែគត់ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធបានចំនួន **៣ ០៤០,៣៧ប៊ីលានរៀល**(ប្រមាណជា **៧៥០,៧១លានដុល្លារ**) ស្មើនឹង **២៦,៦៣ %** នៃផែនការប្រចាំឆ្នាំ។

លទ្ធផលប្រមូលចំណូលពន្ធជាប្រវត្តិសាស្ត្រសម្រាប់ខែមីនា ក៏ដូចជាសម្រាប់ត្រីមាសទី១ឆ្នាំ២០២២នេះមួយភាគធំប្រមូល**បានពីចំណូលពន្ធអាករ**សំខាន់ៗមួយចំនួនដែលរួមមាន÷(១)-**ពន្ធលើប្រាក់ចំណូល (ពន្ធលើប្រាក់ចំណេញ)**ដែលមានចំនួន **២៦៩៨,០២**ប៊ីលានរៀល(ប្រមាណជា **៦៦៦,១៧**លានដុល្លារ)ស្មើនឹង**៥២,៧៥%** នៃចំណូលពន្ធសរុប(២)-**អាករលើតម្លៃបន្ថែម** មានចំនួន **៧៧៤,០២**ប៊ីលានរៀល (ប្រមាណជា **១៩១,១២**លានដុល្លារ) ស្មើនឹង**១៥,១៣%** នៃចំណូលពន្ធសរុប, (៣)-**អាករពិសេសលើទំនិញនិងសេវា** មានចំនួន **២៩៨,៤៧**ប៊ីលានរៀល (ប្រមាណជា **៧៣,៧០**លានដុល្លារ) ស្មើនឹង **៥,៨៣%** នៃចំណូលពន្ធសរុប (៤)-**ពន្ធលើប្រាក់បៀវត្ស**មានចំនួន **៣១៥,០០**ប៊ីលានរៀល (ប្រមាណជា **៧៧,៧៨**លានដុល្លារ) ស្មើនឹង **៦,១៦%** នៃចំណូលពន្ធសរុបនិង(៥)-**ពន្ធប្រថាប់ត្រា** (ផ្ទេរអចលនទ្រព្យ) មានចំនួន**២២៦,៨០** ប៊ីលានរៀល(ប្រមាណជា **៥៦,០** លានដុល្លារ) ស្មើនឹង**៤,៤៣%** នៃចំណូលពន្ធសរុប។

ការកើនឡើងនូវចំណូលពន្ធប្រកបដោយមោទនភាពនាពេលនេះ គឺដោយសារតែការដាក់ចេញនូវមាគ៌ាដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយគតិបណ្ឌិតនិងទស្សនវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលបាននាំមកនូវសុខសន្តិភាព ស្ថិរភាពនយោបាយនិងបរិយាកាសម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពល្អប្រសើរ៕

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានពន្ធដារ*





# មុខងារសវនកម្មផ្ទៃក្នុងនៅក្នុងបរិបទបច្ចេកវិទ្យាព័ត៌មាន

*មុខងារសំខាន់នៃសវនកម្មផ្ទៃក្នុង គឺវាយតម្លៃដោយឯករាជ្យ និងជួយធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ដំណើរការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អ របស់ក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីរួមចំណែកធានាឱ្យគោលបំណង និងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួនសម្រេចបានដោយជោគជ័យតាមការកំណត់។*

ក្នុងបរិការណ៍នៃការវិវឌ្ឍសេដ្ឋកិច្ចសង្គម និងបច្ចេកវិទ្យាព័ត៌មាននិងស្របតាមគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ បូក ២ សម្រាប់ត្រៀមឆ្ពោះទៅអនុវត្តក្នុងដំណាក់កាលទី៤“គណនេយ្យភាពសមិទ្ធកម្ម” ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនិងកិច្ចប្រតិបត្តិការដោយផ្លាស់ជំនួសពីការអនុវត្តដោយដៃទៅជាស្វ័យប្រវត្តិកម្ម។ ក្នុងទិដ្ឋភាពស្វ័យប្រវត្តិកម្មនេះអាចធ្វើឱ្យមានហានិភ័យពាក់ព័ន្ធកើតឡើងដែលទាមទារឱ្យមានការត្រួតពិនិត្យនិងវាយតម្លៃដោយឯករាជ្យដើម្បីធានាបាននូវសុចរិតភាពតម្លាភាពនិងភាពជឿជាក់នៃព័ត៌មាន។ សវនកម្មបច្ចេកវិទ្យាព័ត៌មាននឹងក្លាយជាផ្នែកមួយដ៏សំខាន់នៃការអនុវត្តយន្តការនេះ។



*ភារកិច្ចចម្បងមួយចំនួននៃសវនកម្មបច្ចេកវិទ្យាព័ត៌មានគឺរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសវនកម្មបច្ចេកវិទ្យាព័ត៌មាន,អភិវឌ្ឍជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មាន, រៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម, រៀបចំគោលការណ៍ស្តង់ដារ និងនីតិវិធីអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ប្រព័ន្ធ FMIS, ប្រព័ន្ធគ្រប់គ្រងពន្ធគយអាស៊ីគូដា, ប្រព័ន្ធគ្រប់គ្រងពន្ធដារ, ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ប្រព័ន្ធគ្រប់គ្រងបំណុល..)និងរៀបចំរបាយការណ៍សវនកម្មបច្ចេកវិទ្យាព័ត៌មានជូនថ្នាក់ដឹកនាំអង្គភាព និងថ្នាក់ដឹកនាំ កសហវ.។*

## ក. មូលដ្ឋានជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មាន

លិខិតបទដ្ឋាននានាជាមូលដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ រួមមាន គោលនយោបាយ គោលការណ៍និងស្តង់ដារប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃប្រព័ន្ធFMIS ដែលបានអនុម័ត និងដាក់ឱ្យប្រើប្រាស់តាមលិខិតលេខ ១៣៧ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤, គោលការណ៍ណែនាំសវនកម្មបច្ចេកវិទ្យាព័ត៌មានដែលបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ៥៤៣ សហវ. ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ និងគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មានដែលបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ១០១២ សហវ. ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។

## ខ. ការអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មាន

ការអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មានត្រូវបានប្រព្រឹត្តិឡើងក្រោមការណែនាំពីទីប្រឹក្សាក្នុងស្រុក និងបរទេស និងសម្រេចបានសមិទ្ធផលមួយចំនួនដូចជា÷

- ចុះសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាបន្តបន្ទាប់



នៅលេខាធិការដ្ឋានក្រុមការងារ FMIS អគ្គនាយកដ្ឋានគន្លឹះមួយចំនួននិងអង្គភាពថ្នាក់មូលដ្ឋានបានចំនួន ៨លើក

- ចុះសវនកម្មលើប្រសិទ្ធភាពស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារ(សាខាពន្ធដារខណ្ឌចំការមន សាខាពន្ធដារខណ្ឌសែនសុខសាខាពន្ធដារខេត្តកោះកុង និងសាខាពន្ធដារខេត្តតាកែវ)
- ចុះសវនកម្មលើប្រព័ន្ធគ្រប់គ្រងពន្ធគយអាស៊ីគូដា ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ។ល។
- ចុះសវនកម្មលើការអនុវត្តប្រព័ន្ធFMIS នៅតាមក្រសួង-ស្ថាប័នដែលបានដាក់ឱ្យប្រើប្រាស់ដោយលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងFMIS បានចំនួន ២លើក សរុបចំនួន ៩ក្រសួង (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងឧស្សាហកម្មវិទ្យាសាស្ត្របច្ចេក-វិទ្យានិងនវានុវត្តន៍ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសាធារណការនិង ដឹកជញ្ជូនក្រសួងអភិវឌ្ឍន៍ជនបទនិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)។

លទ្ធផលនៃការចុះសវនកម្មខាងលើត្រូវបានរកឃើញនូវចំណុចខ្វះចន្លោះមួយចំនួននិងត្រូវបានផ្តល់អនុសាសន៍កែលម្អជាបន្តបន្ទាប់។

## គ. ការអភិវឌ្ឍជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្នុងតួនាទីជាអ្នកនាំមុខលើការគាំទ្រជំនាញសវនកម្មផ្ទៃក្នុង បានរៀបចំវគ្គបណ្តុះ-បណ្តាលសិក្ខាសាលា ជាច្រើន÷

- សវនករបច្ចេកវិទ្យាព័ត៌មាននៃកសហវ. ដែលគាំទ្រថវិកាពីអ.គ.ហ.បានចូលរួមវគ្គបណ្តុះបណ្តាលខ្លីលើ ជំនាញបច្ចេកទេសពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មានចំនួន ១០វគ្គមានសវនករចូលរួមសរុប១៥នាក់និងចូលរួមវគ្គបណ្តុះបណ្តាលជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធអនឡាញក្រោមការគាំទ្រពីទីប្រឹក្សាមូលនិធិ-រូបិយវត្ថុអន្តរជាតិជាដំណាក់កាលចំនួន ៣៧ប្រធានបទ មានសវនករផ្ទៃក្នុងរបស់ កសហវ. ចូលរួមសរុប ៣៥នាក់
- សិក្ខាសាលាដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងលើប្រធានបទទាក់ទងទៅនឹងសវនកម្មបច្ចេកវិទ្យាព័ត៌មានជូនសវនករផ្ទៃក្នុងនៅដើមឆ្នាំ២០២២ មានសិក្ខាកាមចូលរួមសរុបចំនួន ២៥០នាក់៕

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃ*
*អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង*





# បច្ច័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើការចូលរួមកែលម្អប្រព័ន្ធហិរញ្ញវត្ថុ និងការផ្តល់សេវាសាធារណៈ

*ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានវាយតម្លៃថាជាកត្តារួមចំណែកមួយដ៏សំខាន់ក្នុងការចូលរួមបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីជំរុញស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកែលម្អការផ្តល់សេវាសាធារណៈនៅក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។*

ប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នូវវិបត្តិនយោបាយនិងសេដ្ឋកិច្ចជាច្រើនដំណាក់កាលដែលបានជះឥទ្ធិពលអវិជ្ជមានដល់គ្រប់វិស័យនិងការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។ចាប់តាំងពីពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០០៤មក, ស្ថានភាពសេដ្ឋកិច្ចត្រូវបានមើលឃើញថាមានបម្រែបម្រួលវិជ្ជមាននិងឈានទៅរកភាពល្អប្រសើរបន្តិចម្តងៗរហូតរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំក្នុងរយៈពេល១ទសវត្សចុងក្រោយដែលការណ៍នេះរុញច្រានឱ្យកម្ពុជាចាកចេញពីភាពក្រីក្រជាបណ្តើរៗ និងលើកកម្ពស់សុខុមាលភាពប្រជាជនកាន់តែប្រសើរឡើង។ទោះជាយ៉ាងនេះក្តី ការផ្សារភ្ជាប់រវាងការអនុវត្តកម្មវិធីកែទម្រង់នេះទៅនឹងស្ថានភាពសេដ្ឋកិច្ចនិងការផ្តល់សេវាសាធារណៈនៅមិនទាន់មានការវាយតម្លៃជាក់លាក់ណាមួយនៅឡើយ។

ដូចនេះ នៅឆ្នាំ២០២១ ការសិក្សាអំពី "បច្ច័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅលើការចូលរួមកែលម្អការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការផ្តល់សេវាសាធារណៈ" ត្រូវបានរៀបចំឡើងដោយ អ.គ.ហ.



ទៅលើសមិទ្ធផលសម្រេចក្នុងកំឡុងឆ្នាំ ២០១៥ ដល់ ២០២០។

*ការសិក្សានេះមានគោលបំណងស្វែងយល់និងវាយតម្លៃអំពីការចូលរួមចំណែករបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការចូលរួមបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីជំរុញស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកែលម្អការផ្តល់សេវាសាធារណៈនៅក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ។*

ការវាយតម្លៃនេះ ផ្តោតលើគោលដៅលទ្ធផលបីដំណាក់កាល រួមមាន÷

**១. បច្ច័យនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈទៅលើការរួមចំណែកកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**២. បច្ច័យនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅលើការចូលរួមពង្រឹងសេដ្ឋកិច្ចនិងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច**

**៣. បច្ច័យនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅលើការកែលម្អ និងការពង្រឹងការផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាលនិងអប់រំ។**

ទំនាក់ទំនងនៃគោលដៅលទ្ធផលទាំងនេះមានលក្ខណៈស្មុគស្មាញ និងគ្មានស្តង់ដារវាយតម្លៃឬឧបករណ៍វាស់វែងជាក់លាក់ឡើយ។ ការវាយតម្លៃឯកសារនេះត្រូវបានផ្អែកលើរបាយការណ៍និងស្តង់ដារវាយតម្លៃផ្សេងៗដែលមានស្រាប់ រួមមាន PEFA, PERs, PETs, QSDS រួមជាមួយនឹងការស្ទង់មតិពិភាក្សា និងការស្រង់ធាតុចូលពីអង្គភាពនិងក្រសួង-ស្ថាប័នពាក់ព័ន្ធ។




*ជាលទ្ធផល, ការវាយតម្លៃនេះបានបញ្ជាក់ថាការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពិតជាកត្តាមួយដែលចូលរួមចំណែកនិងផ្តល់ផលវិជ្ជមានដល់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការផ្តល់សេវាសាធារណៈពិតប្រាកដមែន។*

ជាក់ស្តែងការវាយតម្លៃរកឃើញថា÷

១. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានពង្រឹង និងកែលម្អបន្ទាប់ពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០០៤។ក្នុងន័យនេះតាមរយៈអភិក្រមកែទម្រង់ទាំង៤ដំណាក់កាលការអនុវត្តថវិកា និងការប្រមូលចំណូលជាតិមានភាពល្អប្រសើរបន្តិចម្តងៗតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រនានា ដូចជា យុទ្ធសាស្ត្រកៀរគរចំណូលជាដើម, ការកត់ត្រាចំណូលចំណាយត្រូវបានបញ្ចូលក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ FMIS ជាបណ្តើរៗ, ការរៀបចំក្របខណ្ឌថវិកាត្រូវបានបង្កើតស្របជាមួយនឹងការរៀបចំផែនការថវិការបស់ក្រសួង-ស្ថាប័នកំពុងបន្តពង្រឹង និងកែលម្អឱ្យមានការផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្រៅពីនេះឯកសារច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗបាន នឹងកំពុងបន្តរៀបចំកែលម្អសម្រាប់ជាគោលការណ៍ណែនាំក៏ដូចជាផែនទីចង្អុលទិសក្នុងការឈានទៅដាក់ឱ្យអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មនាពេលខាងមុខ។

២. សមិទ្ធផលនៃការអនុវត្តសេដ្ឋកិច្ច នៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយ(២០១៥-២០២០)មានកំណើនថេរពោលក្នុងរង្វង់៧% ជាមួយនឹងអត្រាអតិផរណាជាមធ្យម៣% ក្នុងមួយឆ្នាំ។ ជាមួយគ្នានេះ ទុនបម្រុងរបស់រដ្ឋាភិបាលត្រូវបានបង្កើនពី ៦.៨ ប៊ីលានដុល្លារនៅឆ្នាំ២០១៥ ដល់ ២១.៣ ប៊ីលានដុល្លារនៅឆ្នាំ២០២០ដែលរក្សានូវភាពរឹងមាំនៃលំហសារពើពន្ធ(fiscal space) ក្នុងកំឡុងពេលមានវិបត្តិជំងឺកូវីដ-១៩ នៅឆ្នាំ២០២០។ សមិទ្ធផលវិជ្ជមានទាំងនេះត្រូវបានរួមចំណែកយ៉ាងធំពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលអាចឆ្លុះបញ្ចាំងបានតាមរយៈយុទ្ធសាស្ត្រកែទម្រង់ផ្សេងៗរួមមានយុទ្ធសាស្ត្រកៀរគរចំណូលដែលជំរុញឱ្យមានកំណើននៃចំណូលក្នុងស្រុក, យុទ្ធសាស្ត្រគ្រប់គ្រងការវិនិយោគសាធារណៈ, យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈជាដើម។

៣. សមិទ្ធផលនៃការអនុវត្តសេវាសាធារណៈ នៅក្នុងវិស័យសុខាភិបាលនិងអប់រំមានភាពល្អប្រសើរច្រើននៅក្នុងរយៈពេលដូចគ្នា។ ជាក់ស្តែង ការចុះឈ្មោះសិក្សា និងអត្រាបញ្ចប់ការសិក្សារបស់សិស្សានុសិស្សកម្រិតបឋមសិក្សានិងមធ្យមសិក្សាមានការកើនឡើងស្របជាមួយនឹងការផ្គត់ផ្គង់គ្រូបង្រៀននិងឧបករណ៍អប់រំស្របតាមស្តង់ដារWASH ត្រូវបានបង្កើនផងដែរ។ លទ្ធផលសិក្សារបស់សិស្សានុសិស្សថ្នាក់ទី៣លើការអាននិងមុខវិជ្ជាគណិតវិទ្យាមានភាពរីកចម្រើនច្រើន។ ដោយឡែកវឌ្ឍនភាពវិជ្ជមាននៃសុខុមាលភាពប្រជាជនត្រូវបានមើលឃើញតាមរយៈការថយចុះនៃអត្រាមរណមាតា ពី ៤៨៨នាក់ នៅឆ្នាំ២០០០ ដល់១៦០នាក់ នៅឆ្នាំ២០១៧ សម្រាប់ការផ្តល់កំណើត១០០០០នាក់ ខណៈដែលចំនួនអ្នកកើតជំងឺផ្សេងៗមានការថយចុះយ៉ាងគំហុកនៅឆ្នាំ២០១៥។ ប្រសិទ្ធភាពនិងភាពរលូននៃការអនុវត្តសេវាសាធារណៈត្រូវបានចូលរួមចំណែកយ៉ាងសំខាន់ពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជាពិសេសចំណូលដែលរាជរដ្ឋាភិបាលបានកៀរគរពីប្រភពនានាត្រូវបានបង្កើនទំហំ និងវិភាជន៍ថវិកាជូនវិស័យទាំងពីរលើការរៀបចំបៀវត្សនិងការអនុវត្តចំណាយផ្សេងៗទាន់ពេលវេលាតម្លាភាព និងស័ក្តិសិទ្ធិភាព។

លទ្ធផលនៃការវាយតម្លៃទាំងនេះនឹងក្លាយជាធាតុចូលសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀតក្នុងកិច្ចសហការដើម្បីបន្តកែលម្អលើការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព៕

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍នៃ អ.ត.ហ.*




**ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០**

Acronym

PEFA : Public Expenditure and Financial Accountability

PERs : Public Expenditure Reviews

PETs : Public Expenditure Tracking

QSDS : Quantifiable Service Delivery Survey

WASH : Water, Sanitation and Hygiene

# សញ្ញាណទូទៅនៃវិធីសាស្ត្រវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ(MAPS)

*ទិន្នន័យនៃលទ្ធកម្មសាធារណៈបង្ហាញថា ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលនៃបណ្តាប្រទេសនៅលើពិភពលោកបានចំណាយប្រហែល ៩.៥ទ្រីលានដុល្លារអាមេរិក ដែលនេះជាទំហំមួយគួរឱ្យកត់សម្គាល់។ បើគិតជាមធ្យមវិញ លទ្ធកម្មសាធារណៈនៃប្រទេសនីមួយៗ មានទំហំប្រមាណ ១២% ទៅ ២០% នៃផលិតផលក្នុងស្រុកសរុប។ នេះមានន័យថា លទ្ធកម្មសាធារណៈមិនត្រឹមតែជាការទិញទំនិញឬសេវាកម្មដោយរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឧបករណ៍មួយដែលរដ្ឋអាចប្រើដើម្បីសម្រេចគោលនយោបាយរបស់ខ្លួនផងដែរ។*

លទ្ធកម្មសាធារណៈគឺជាធាតុមួយដ៏សំខាន់នៃការផ្គត់ផ្គង់សេវាសាធារណៈអភិបាលកិច្ចល្អនិងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន។ ហេតុនេះ គេចាំបាច់ត្រូវមានវិធីសាស្ត្រសម្រាប់វាយតម្លៃលទ្ធកម្មសាធារណៈដែលមានភាពសត្យានុម័តនិងគ្រប់ជ្រុងជ្រោយ។

ជាការឆ្លើយតបនឹងតម្រូវការនេះវិធីសាស្ត្រវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ (Methodology for Assessing Procurement Systems) ហៅកាត់ថា MAPS ត្រូវបានបង្កើតឡើង និងកែសម្រួលជាបន្តបន្ទាប់ដោយមានការសហការរវាងបណ្តាប្រទេសនិងដៃគូពាក់ព័ន្ធជាច្រើន។ MAPSគឺជាស្តង់ដាអន្តរជាតិនិងជាឧបករណ៍សកលសម្រាប់វាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈដែលគេអាចប្រើចំពោះគ្រប់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅគ្រប់កម្រិតរដ្ឋបាល(ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) និងគ្រប់កម្រិតអភិវឌ្ឍន៍(ទាំងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍)។

MAPS ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣-២០០៤និងត្រូវបានកែសម្រួលនៅឆ្នាំ២០១៥-២០១៧ ឱ្យសមស្របទៅនឹងបម្រែបម្រួលនៃប្រព័ន្ធសេដ្ឋកិច្ចសាកលនិងប្រព័ន្ធលទ្ធកម្មសាធារណៈដែលកាន់តែមានភាពស្មុគស្មាញឡើង។ ការកែសម្រួលនេះយោងទៅតាមអនុសាសន៍ក្រុមប្រឹក្សាលទ្ធកម្មសាធារណៈ (ឆ្នាំ២០១៥) នៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)និងឆ្លុះបញ្ចាំងពីក្របខណ្ឌលទ្ធកម្មអន្តរជាតិឈានមុខគេដូចជាច្បាប់គំរូស្តីពីលទ្ធកម្មសាធារណៈ(ឆ្នាំ២០១១) នៃគណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ(UNCITRAL) សេចក្តីណែនាំស្តីពីលទ្ធកម្មសាធារណៈ (ឆ្នាំ២០១៤) នៃសហភាពអឺរ៉ុប (EU), និងក្របខណ្ឌលទ្ធកម្មដទៃទៀតដែលប្រើដោយធនាគារអភិវឌ្ឍន៍ពហុភាគី និងស្ថាប័នអនុវត្តន៍នានា។ វិធីសាស្ត្រនេះមានរចនាសម្ព័ន្ធជាក់លាក់ដដែលគេហៅថាគំនិតផ្តួចផ្តើម MAPS (MAPS Initiative) ដូចបង្ហាញក្នុង រូបទី១ ខាងក្រោម។ គំនិតផ្តួចផ្តើម




***រូបភាពទី១÷ រចនាសម្ព័ន្ធនៃគំនិតផ្តួចផ្តើម** MAPS (MAPS Initiative)*

នេះកើតឡើងពី÷

**១)** បណ្តាញ MAPS ÷ សំដៅលើក្រុមនៃប្រទេស និងស្ថាប័នដែលគាំទ្រការអនុវត្តឬដែលធ្លាប់ត្រូវបានគេវាយតម្លៃដោយវិធីសាស្ត្រនេះពីមុនមក។

**២)** គណៈកម្មាធិការដឹកនាំ ÷ មានតួនាទីត្រួតពិនិត្យសកម្មភាពការងាររបស់លេខាធិការដ្ឋាន ដែលសមាជិកនៃគណៈកម្មាធិការដឹកនាំរួមមានអ្នកផ្តល់ហិរញ្ញប្បទានចម្បង និងអ្នកតំណាងនៃបណ្តាញ MAPS។

**៣)** លេខាធិការដ្ឋាន ÷ មានតួនាទីជាអ្នកសម្របសម្រួល គាំទ្រ និងធានាគុណភាពនៃរាល់ការវាយតម្លៃ។

**៤)** ក្រុមប្រឹក្សាបច្ចេកទេស ÷ ជាអ្នកត្រួតពិនិត្យឡើងវិញផ្នែកបច្ចេកទេសទៅលើការវាយតម្លៃដោយប្រើ MAPS និងបង្កើតឡើងចេញពីបណ្តាញMAPS សម្រាប់ការវាយតម្លៃនីមួយៗ។

MAPS មានគោលដៅពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃលទ្ធកម្មសាធារណៈធានាឱ្យបាននូវសង្គតិភាពនិងតម្លាភាពនៃការវិភាជនិងប្រើប្រាស់ធនធានសាធារណៈនិងជំរុញការពិភាក្សារវាងភាគីពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ។ ការវាយតម្លៃដោយប្រើ MAPS បង្ហាញពីចំណុចខ្លាំងនិងចំណុច-ខ្សោយនៃប្រព័ន្ធលទ្ធកម្មសាធារណៈនិងផ្តល់ជាមូលដ្ឋានវិភាគសម្រាប់ការកែទម្រង់ច្បាស់លាស់ ព្រមទាំងរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់ការអនុវត្តនិងតាមដានការកែទម្រង់។ ក្នុងន័យនេះ MAPSគឺជាឧបករណ៍មួយសម្រាប់កំណត់កាលានុវត្តភាពបញ្ហាប្រឈមនិងវឌ្ឍនភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

គួរបញ្ជាក់ផងដែរថាMAPS មិនមែនជាវិធីសាស្ត្រដាច់ដោយឡែកពីវិធីសាស្ត្រវាយតម្លៃដទៃទៀត ដូចជា TADAT សម្រាប់វាយតម្លៃប្រព័ន្ធពន្ធដារ និង PEFA សម្រាប់វាយតម្លៃហិរញ្ញវត្ថុសាធារណៈនោះទេប៉ុន្តែជាឧបករណ៍មួយក្នុងក្របខណ្ឌវាស់វែងលទ្ធផលដែលរដ្ឋាភិបាលប្រើប្រាស់ក្នុងការវាយតម្លៃស្ថានភាពនៃប្រព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។MAPSមានគោលការណ៍គ្រឹះមួយចំនួន ដូចជា ១) តម្លៃនៃលុយ ២) តម្លាភាព ៣) សមភាពនិង៤) អភិបាលកិច្ចល្អ។ តម្លៃនៃលុយសំដៅលើគោលដៅចម្បងដែលរាល់ប្រព័ន្ធលទ្ធកម្មសាធារណៈគួរសម្រេចបាន គឺការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មស្របតាមតម្រូវការ និងប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។ តម្លាភាពសំដៅលើការផ្តល់ជូនសាធារណៈជននូវព័ត៌មានអំពីក្របខណ្ឌគតិយុត្តគោលនយោបាយនិងស្ថាប័ននិងការសម្រេចចិត្តទាំងឡាយទាក់ទងនឹងលទ្ធកម្មសាធារណៈ ដែលព័ត៌មាននោះត្រូវមានភាពងាយយល់ងាយរកបាននិងទាន់ពេលវេលា។ដោយ-ឡែកសមភាពមានន័យថាកិច្ចលទ្ធកម្មត្រូវមានភាពមិនលម្អៀងនិងស្មើភាពគ្នាជានិច្ច។ ចំណែកអភិបាលកិច្ចល្អវិញ សំដៅលើបរិយាកាសទូទៅនៃអភិបាលកិច្ច ដែលអនុគ្រោះនិងជំរុញឱ្យមានការអនុវត្តនិងកែទម្រង់លទ្ធកម្មសាធារណៈ។

ក្របខណ្ឌវិភាគរបស់ MAPS អាចបែងចែកជាពីរផ្នែកសំខាន់គឺ វិធីសាស្ត្រវាយតម្លៃស្នូលនិងម៉ូឌុលបន្ថែមមួយចំនួន។ វិធីសាស្ត្រស្នូលផ្តល់នូវអភិក្រមគ្រប់ជ្រុងជ្រោយមួយសម្រាប់វាយតម្លៃដោយធ្វើការកំណត់រចនាសម្ព័ន្ធសម្រាប់វិភាគបរិការណ៍ប្រទេសផ្តល់នូវប្រព័ន្ធសូចនាករមួយដែលផ្តោតលើលទ្ធផល និងសមិទ្ធផល និងពណ៌នាធាតុគន្លឹះសម្រាប់ដំណើរការវាយតម្លៃ។ ដោយឡែកម៉ូឌុលបន្ថែមវិញត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ដើម្បីបំពេញបន្ថែមវិធីសាស្ត្រវាយតម្លៃស្នូលដោយផ្តោតលើផ្នែកណាមួយនៃលទ្ធកម្មសាធារណៈទៅតាមសេចក្តីត្រូវការរបស់ប្រទេសនីមួយៗ។

\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\

*ការវិភាគបរិការណ៍ប្រទេសគឺជាការសិក្សាអំពីស្ថានភាពទូទៅនៃប្រទេសមួយដោយប្រើប្រាស់ព័ត៌មាន និងទិន្នន័យដែលមានស្រាប់និងងាយរកបាន។ ការសិក្សានេះផ្តោតទៅលើកត្តាសំខាន់ៗសម្រាប់ការកែទម្រង់លទ្ធកម្មសាធារណៈរួមមានស្ថានភាពសេដ្ឋកិច្ចគោលនយោបាយជាតិ បរិយាកាសសម្រាប់ការកែទម្រង់ និងទំនាក់ទំនងរវាងប្រព័ន្ធលទ្ធកម្មសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធរដ្ឋបាលសាធារណៈ។*

\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\\

ប្រព័ន្ធសូចនាករ MAPS មានសសរស្តម្ភចំនួន៤ គឺ÷

**១) ក្របខណ្ឌគតិយុត្ត និងគោល-នយោបាយ÷** ផ្ដោតលើវិធាន និងនីតិវិធីផ្លូវការសម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈ និងធ្វើការប្រៀបធៀបប្រព័ន្ធដែលមានស្រាប់ទៅនឹងស្តង់ដារអន្តរជាតិ។

**២) ក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រង÷** ផ្ដោតទៅលើដំណើរការនៃប្រព័ន្ធលទ្ធកម្មសាធារណៈនៅកម្រិតស្ថាប័ន និងប្រព័ន្ធគ្រប់គ្រង។

**៣) ប្រតិបត្តិការលទ្ធកម្ម និងការអនុវត្តទីផ្សារ÷** មើលទៅលើប្រសិទ្ធភាពប្រតិបត្តិការ តម្លាភាព និងភាពនៃប្រព័ន្ធនៅកម្រិតអង្គភាពលទ្ធកម្ម ដែលទទួលបន្ទុកអនុវត្តលទ្ធកម្មនីមួយៗ។

**៤) គណនេយ្យភាព សុចរិតភាព និងតម្លាភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ÷** ផ្ដោតសំខាន់ទៅលើចំណុចមួយចំនួនដូចជាការចូលរួមនៃសង្គមស៊ីវិលប្រព័ន្ធសវនកម្មវិធានការប្រឆាំងអំពើពុករលួយ និងយន្តការដោះស្រាយបណ្ដឹងដែលជាកត្តាកំណត់នៃ ប្រព័ន្ធលទ្ធកម្មសាធារណៈ។

សសរស្តម្ភនីមួយៗនៃប្រព័ន្ធសូចនាករ MAPS មានសូចនាករនិងអនុសូចនាករបន្ថែមទៀតដែលខ្លះជាសូចនាករគុណភាព និងខ្លះទៀតជាសូចនាករបរិមាណ។ ប្រព័ន្ធសូចនាករនេះមានសូចនាករសរុបចំនួន១៤និងអនុសូចនាករសរុបចំនួន ៥៥។

ជាការពិតណាស់ MAPS មិនមែនជាវិធីសាស្ត្រល្អឥតខ្ចោះដែលអាចពន្យល់ប្រព័ន្ធលទ្ធកម្មសាធារណៈបានទាំងស្រុងនោះទេ។ ប៉ុន្តែគេយល់ឃើញថា MAPS អាចជួយបង្ហាញពីចំណុចខ្លាំងនិងចំណុចខ្សោយនៃប្រព័ន្ធលទ្ធកម្មសាធារណៈហើយការរកឃើញចំណុចទាំងនោះគឺជាគន្លឹះដ៏សំខាន់សម្រាប់ការងារកែទម្រង់។ រូបភាពទី២ ខាងក្រោមនេះបង្ហាញពីទិដ្ឋភាពរួមរបស់ MAPS។

MAPS ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ។ ជាក់ស្តែងនៅប៉ុន្មានឆ្នាំចុងក្រោយនេះប្រទេសមួយចំនួនដូចជា ណ័រវ៉េស ប៉េរូ ម៉ុលដូវ៉ា និងលីបង់ បានប្រើវិធីសាស្ត្រមួយនេះដើម្បីវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈនិងរៀបចំយុទ្ធសាស្ត្រនិងផែនការសម្មភាពសម្រាប់ការកែទម្រង់។

*សម្រាប់កម្ពុជាផ្អែកតាមផែនការសកម្មភាពលម្អិតនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) និងសហការរៀបចំ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈដើម្បីវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈនៅកម្ពុជា ដោយប្រើវិធីសាស្ត្រ MAPS នេះផងដែរ។*

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកានៃ អ.គ.ហ.*


*ឯកសារយោង*

*MAPS (2018), "Methodology for Assessing Procurement Systems (MAPS) 2018",*

*https://www.mapsinitiative.org/methodology/MAPS-methodology-for-assessing-procurement-systems.pdf*





***រូបភាពទី២៖ ទិដ្ឋភាពរួមរបស់*** *MAPS*



ផ្នែកទី ៣
សន្ទរកថា

# សុន្ទរកថា ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី គោលនយោបាយ និងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

*- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ**, ឯកឧត្តមរដ្ឋមន្ត្រី **ជា វ៉ាន់ដេត***

*- ឯកឧត្តម, លោកជំទាវ, ឯកអគ្គរាជទូត, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីរាប់អាន!*



ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយសនិងក្តីសោមនស្សក្រៃលែង ដោយបានមកចូលរួមថ្លែងសុន្ទរកថាបើកក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី"គោលនយោបាយនិងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា" ។ ឆ្លៀតឱកាសដ៏ប្រពៃនេះ, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅនិងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ, តំណាងស្ថានទូត, ដៃគូអភិវឌ្ឍន៍, គ្រឹះស្ថានហិរញ្ញវត្ថុធនាគារនិងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, ធុរជននិងនវានុវត្តជនដែលមានវត្តមាននៅក្នុងកម្មវិធីនេះ, ទាំងនៅទីនេះដោយផ្ទាល់, និងទាំងពីចម្ងាយតាមប្រព័ន្ធអនឡាញ។

ខ្ញុំសូមអរគុណចំពោះ ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដែលបានផ្តល់របាយការណ៍អំពីទិដ្ឋភាពទូទៅនិងអំពីអត្ថប្រយោជន៍នៃវិស័យសេដ្ឋកិច្ចឌីជីថល, ជាពិសេសអំពីការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ(FinTech) នៅកម្ពុជា។ ខ្ញុំក៏សូមអគុណចំពោះឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា សម្រាប់សុន្ទរកថាស្វាគមន៍យ៉ាងកក់ក្តៅ និងប្រកបដោយអត្ថន័យដែលក្នុងនោះឯកឧត្តមបានអត្ថាធិប្បាយប្រកបដោយខ្លឹមសារពេញលេញអំពីស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា។





ថ្ងៃនេះ, យើងមានឱកាសជួបជុំគ្នាដោយផ្ទាល់ម្តងទៀតនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីគោលនយោបាយនិងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។ ខ្ញុំនៅចាំបានថា, ខ្ញុំបានធ្វើជាអធិបតីនៅក្នុងសិក្ខាសាលាស្រដៀងគ្នានេះគឺនៅក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិស្តីពី “គោលនយោបាយនិង ទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា” នាខែមីនា ឆ្នាំ២០១៩ តែប៉ុន្មានខែមុននឹងការរីករាលដាលនៃមេរោគជំងឺកូវីដ-១៩នៅចុងឆ្នាំ២០១៩។ ការគិតគូររៀបចំគោលនយោបាយនៅពេលនោះបានដើរស្របនឹងបន្ទាត់ពេលវេលានៃតម្រូវការក្នុងការធ្វើបរិវត្តកម្មឌីជីថលដែលជួយឱ្យយើងអាចឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩។ យ៉ាងណាមិញ, សម្រាប់សិក្ខាសាលាថ្ងៃនេះ នាឆ្នាំ២០២៣, យើងស្ថិតនៅក្នុងដំណើរនៃការងើបឡើងវិញចេញពីវិបត្តិជាប្រវត្តិសាស្ត្រនៃមនុស្សជាតិហើយក៏ស្របពេលដែលមានតម្រូវការនៃការគិតគូរជាសកលអំពីការជំរុញប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការស្តារសេដ្ឋកិច្ច និងសង្គមឡើងវិញ។ លើមូលដ្ឋាននេះ, គោលបំណងសំខាន់ៗនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនេះ គឺដើម្បីប្រមូលធាតុចូលពីអ្នកចូលរួមទាំងអស់សម្រាប់កំណត់ទិសដៅ និងរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា និងដើម្បីលើកកម្ពស់ការយល់ដឹងអំពីការវិវត្តនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ននិងបញ្ហាប្រឈម នានាដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់នៅកម្ពុជា។




*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

នៅក្រោមម្លប់នៃសុខសន្តិភាពក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក ដែលជាសមិទ្ធផលមិនអាចកាត់ថ្លៃបាននាំមកប្រជាជាតិយើងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ក្រៅពីការកសាងសមិទ្ធផលរូបវន្ត, រាជរដ្ឋាភិបាលក៏បាន និងកំពុងបន្តខិតខំរៀបចំនិងដាក់ចេញនូវគោលនយោបាយនិងវិធានការជាបន្តបន្ទាប់ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមនានាទាំងក្នុងផ្នែកសេដ្ឋកិច្ចនិងសង្គម, សំដៅធានា ឱ្យបាននូវភាពអំណោយផលនៃបរិយាកាសធុរកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ទាក់ទាញការវិនិយោគ និងពាណិជ្ជកម្ម, និងជាពិសេស, សំដៅពន្លឿនការធ្វើពិពិធកម្មនិងពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា។

ជាអកុសល, ការរីករាលដាលនៃជំងឺកូវីដ-១៩, ដែលបានចាប់ផ្តើមឡើងនៅដើមឆ្នាំ២០២០, បានជះឥទ្ធិពលអវិជ្ជមានមិនធ្លាប់មាន ដល់ផ្នែកសុខាភិបាល និងសង្គមសេដ្ឋកិច្ច, ទាំងក្នុងក្របខណ្ឌសកល, តំបន់ និងផ្ទៃក្នុងប្រទេស។ ក្នុងបរិការណ៍នេះ, មិនខុសពីបណ្តាប្រទេសដទៃក្នុងពិភពលោក, កម្ពុជាដែលមានសេដ្ឋកិច្ចបើកចំហនិងងាយប្រែប្រួលទៅនឹងចរន្តសេដ្ឋកិច្ចខាងក្រៅបានទទួលរងផលប៉ះទង្គិចនិងការបន្ទចបង្អាក់ទាំងក្នុងទិដ្ឋភាពសង្គមនិងសេដ្ឋកិច្ច។ ជាក់ស្តែង, ក្នុងឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចជាតិបានធ្លាក់ចុះក្នុងអត្រា -៣,១% ដោយសារការធ្លាក់ចុះនៃតម្រូវការសកល, ភាពរអាក់រអួលនៃខ្សែច្រវាក់ផលិតកម្មសកលនិងតំបន់, ការធ្លាក់ចុះនៃរំហូរមនុស្សនិងការបាត់បង់ទំនុកចិត្តក្នុងការវិនិយោគ។ ត្រង់ចំណុចនេះ, ខ្ញុំក៏សូមគូសបញ្ជាក់ថាសេដ្ឋកិច្ចកម្ពុជាអាចនឹងរងផលប៉ះពាល់អាក្រក់ច្រើនជាងនេះក្នុងករណីពុំមានការដាក់ចេញវិធានការអន្តរាគមន៍ទាន់ពេល ប្រកបដោយភាពបត់បែននិងប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល, ជាបន្តបន្ទាប់កន្លងមក, សំដៅធានាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និង

រក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជនក្នុងលទ្ធភាពដែលអាចទ្រទ្រង់បាន។

រហូតមកដល់ពេលនេះ, ក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ជាមួយនឹងស្មារតីបុរេសកម្ម និងភាពប្រយ័ត្នប្រយែងខ្ពស់, រាជរដ្ឋាភិបាលបានដាក់ចេញនូវកញ្ចប់វិធានការអន្តរាគមន៍ចំនួន ១០ជុំ ជាបន្តបន្ទាប់រួចមក ដើម្បីជួយស្រោចស្រង់វិស័យឯកជន និងរក្សាលំនឹងជីវភាពរស់នៅរបស់កម្មករនិយោជិតបម្រើការក្នុងវិស័យសំខាន់ៗដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។ ជាមួយគ្នានេះផងដែរ, រាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រគន្លឹះដើម្បីផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩, ទាំងដូសមូលដ្ឋាននិងដូសជំរុញ, ជូនប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនិងគ្រប់ទីតាំងភូមិសាស្ត្រ។ ជាលទ្ធផល, កម្ពុជាសម្រេចបានអត្រាខ្ពស់នៃចំនួនប្រជាជនទទួលបានវ៉ាក់សាំងរហូតដល់ជាង៩០% នៃប្រជាជនសរុបដែលបាន និងកំពុងបង្កើត និងបង្កើនភាពស៊ាំសហគមន៍។ ជាក់ស្តែង, ការជួបជុំគ្នានៅថ្ងៃនេះដោយផ្ទាល់ក្នុងរយៈពេលជាង ១សប្តាហ៍ក្រោយពីការប្រារព្ធពិធីចូលឆ្នាំខ្មែរជាធម្មតានាឆ្នាំនេះបានបង្ហាញថា ភាពស៊ាំសហគមន៍របស់យើងមានភាពរឹងមាំ ដែលនឹងបន្តអនុញ្ញាតឱ្យកម្ពុជាមានទំនុកចិត្តកាន់តែខ្លាំងថែមទៀតក្នុងការបើកប្រទេសនិងសកម្មភាពសេដ្ឋកិច្ចសង្គមពេញលេញឡើងវិញ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២១ មក, ដំណើរការចាក់វ៉ាក់សាំងជាសកលសម្រេចបានវឌ្ឍនភាពល្អប្រសើរដែលបានក្លាយជាមូលដ្ឋានចាំបាច់សម្រាប់ការគិតគូរដាក់ចេញនូវយុទ្ធសាស្ត្រនិងគោលនយោបាយនានា ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញ ដោយជារួម បាននិងកំពុងអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ច, ទាំងក្នុងកម្រិតជាតិនិងឆ្លងដែនមានភាពសកម្មនិងបន្តមុខងារជាប្រក្រតីឡើងវិញ។ ជាក់ស្តែង, សេដ្ឋកិច្ចសកលបានបង្ហាញសញ្ញាងើបឡើងវិញបន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ២០២០និងត្រូវបានវាយតម្លៃថាសម្រេចបានកំណើនប្រមាណ ៦,១% ក្នុងឆ្នាំ២០២១ និង៣,៦% ក្នុងឆ្នាំ២០២២ដោយសារការដាក់ចេញនូវគោលនយោបាយគាំទ្រផ្សេងៗជាច្រើន, ទាំងផ្នែករូបិយវត្ថុ និងផ្នែកសារពើពន្ធ, គួបផ្សំនឹងការបន្តចាក់វ៉ាក់សាំងបានទូលំទូលាយទាំងក្នុងកម្រិតសកលនិងតំបន់, សំដៅកាត់បន្ថយផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងជំរុញកំណើនសេដ្ឋកិច្ច។




ទោះជាយ៉ាងនេះក្តី, លទ្ធភាពនៃការលេចឡើងនូវរលកចម្លងនៃជំងឺកូវីដ-១៩ បណ្តាលមកពីវីរុសបំប្លែងខ្លួនថ្មីៗ, សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា និងភាពកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយ និងបន្ទាប់ពីមានការលេចឡើងនូវសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន គឺជាហានិភ័យចំពោះមុខដែលបាននិងកំពុងនាំមកនូវបច្ច័យអវិជ្ជមានយ៉ាងស្រួចស្រាល់និងបន្តដាក់សម្ពាធលើមាគ៌ាងើបឡើងវិញ(recovery pathway)នៃសេដ្ឋកិច្ចសកល តាមរយៈការបង្អាក់ដំណើរការនៅតំបន់តំណភ្ជាប់សំខាន់ៗ នៃច្រវាក់ផលិតកម្មសកល និងការកើនឡើងនូវថ្លៃថាមពលដែលជាលទ្ធផលបង្កឱ្យមានការកើនឡើងនូវថ្លៃទំនិញគ្រប់ប្រភេទ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ស្ថិតក្នុងបរិបទនេះ, រាជរដ្ឋាភិបាលបន្តប្តេជ្ញាជំរុញពន្លឿនវឌ្ឍនភាពនៃការអនុវត្តការដ្ឋានកែទម្រង់ឱ្យកាន់តែស៊ីជម្រៅសំដៅកសាងប្រព័ន្ធសេដ្ឋកិច្ចនិងសង្គមឱ្យកាន់តែរឹងមាំនិងមានភាពធន់ទៅនឹងវិបត្តិនាអនាគតជាពិសេសឆ្លើយតបបានទាន់ពេលវេលាទៅនឹងនិន្នាការសំខាន់ៗនិងការវិវត្តយ៉ាងឆាប់រហ័សនៃព្រឹត្តិការណ៍នានាក្នុងតំបន់និងសកល។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងគោលបំណង“ស្តារសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និងរយៈពេលមធ្យមឱ្យត្រឡប់ទៅវិថីនៃកំណើនជាសក្តានុពលរបស់ខ្លួននិងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្នក្នុងរយៈពេលវែង” ដែលក្នុងនោះបានគូសរំលេចអំពីសារៈសំខាន់នៃការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) ក្នុងវិស័យសាធារណៈនិងឯកជនដើម្បីជំរុញល្បឿននៃការស្តារសេដ្ឋកិច្ចជាតិឱ្យបានលឿននិងឆាប់រហ័សផងដែរ។

ក្នុងយុគសម័យសកលភាវូបនីយកម្មឌីជីថលដែលមានបដិវត្តន៍ឧស្សាហកម្ម ៤.០ ជានិន្នាការដឹកមុខ, បច្ចេកវិទ្យាឌីជីថលបានបោះជំហានយ៉ាងលឿនហើយបានក្លាយជាកត្តាគន្លឹះសម្រាប់ជំរុញការគ្របដណ្តប់និងការតភ្ជាប់បណ្តាសេដ្ឋកិច្ចនិងសង្គមនៅទូទាំងពិភពលោកឱ្យកាន់តែស្អិតរមួត, ខិតជិតគ្នានិងអាស្រ័យគ្នាទៅវិញទៅមក។ រហូតមកដល់បច្ចុប្បន្ននេះ, គ្រប់វិស័យសេដ្ឋកិច្ចរាប់ទាំងវិស័យឧស្សាហកម្ម សេវាកម្ម កសិកម្ម និងហិរញ្ញវត្ថុ, តំបន់ភូមិសាស្ត្រ ទាំងទីប្រជុំជន និងជនបទ, ព្រមទាំងបុគ្គល ទាំងវ័យក្មេង និងចំណាស់, សុទ្ធសឹងទទួលរងឥទ្ធិពលពីបច្ចេកវិទ្យាជាពិសេសបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននិងបច្ចេកវិទ្យាឌីជីថលដែលបាននិងកំពុង÷ (១). កែប្រែរបៀបក្នុងការធ្វើធុរកិច្ចឬម៉ូដែលធុរកិច្ច; (២). ផ្លាស់ប្តូរទម្លាប់រស់នៅឬជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទូទៅក្នុងការប្រាស្រ័យទាក់ទង, ការស្វែងរកការងារ, ការពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងការបង្កើតគំនិតច្នៃប្រឌិត; (៣). ធ្វើឱ្យល្អប្រសើរនូវការផ្តល់សេវាសាធារណៈ, ទាំងវិសាលភាពនិងគុណភាពរបស់រដ្ឋាភិបាល។

មិនថាស្ថិតក្នុងកម្រិតអភិវឌ្ឍន៍បែបណា (regardless of development stage) នោះឡើយ, បច្ចេកវិទ្យាឌីជីថលអាចមានសក្តានុពលខ្ពស់និងទូលំទូលាយក្នុងការផ្តល់លទ្ធភាពឱ្យបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ឬកំពុងអភិវឌ្ឍអាចចាប់យកបច្ចេកវិជ្ជាថ្មីៗនិងលោតផ្លោះពីឧស្សាហកម្មប្រពៃណី ទៅឧស្សាហកម្មទំនើបបានក្នុងរយៈពេលដ៏ខ្លីតាមរយៈ÷

(១). ការវិវត្តខ្លួនជាវិស័យ ចន្ទល់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច,

(២). ការប្រែក្លាយជាកាតាលីករក្នុងការគាំទ្រនិងជំរុញសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀតជាពិសេសវិស័យជំរុញកំណើនមានស្រាប់ ឱ្យមានផលិតភាពខ្ពស់;

(៣). ការផ្តល់លទ្ធភាពឱ្យធុរជន និងវិនិយោគិនក្នុងស្រុក អាចភ្ជាប់ខ្លួនទៅនឹងខ្សែ ច្រវាក់ផលិតកម្មតំបន់ និងសកល ក៏ដូចជាស្វែងរកភាពច្នៃប្រឌិតក្នុងការផលិតទំនិញ និងសេវាកម្ម។ ដោយមើលឃើញពីសក្តានុពលនៃវិស័យបច្ចេកវិទ្យាឌីជីថលនេះ, រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្ត "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ កាលពីឆ្នាំ២០២១ និងបានដាក់ឱ្យអនុវត្តជាផ្លូវការនូវ"**គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥**" ក្នុងឆ្នាំ២០២២នេះដែលជាក្របខណ្ឌរួមក្នុងគោលដៅជំរុញដំណើរការបរិវត្តកម្មឌីជីថល លើគ្រប់តួអង្គ ក្នុងសេដ្ឋកិច្ចសង្គមជាតិកម្ពុជាទាំងមូល។ តាមរយៈនេះ, គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវបានបង្កើតឡើងជាយន្តការស្ថាប័នដឹកនាំសម្របសម្រួលអនុវត្តគោលនយោបាយឱ្យសម្រេចបានជោគជ័យផងដែរ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ឧស្សាហកម្មហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានចែកចេញជា២ធំៗ រួមមាន÷

(ទី១). វិស័យហិរញ្ញវត្ថុធនាគារ ស្ថិតក្រោមការគ្រប់គ្រង, ការត្រួតពិនិត្យ, និងបញ្ញត្តិកម្មរបស់ធនាគារជាតិនៃកម្ពុជា

(២). វិស័យហិរញ្ញវត្ថុមិនមែនធនាគារដែលគ្របដណ្តប់វិស័យធានារ៉ាប់រងនិងសោធនឯកជន, មូលបត្រ, សន្តិសុខសង្គម, បរធនបាលកិច្ច, គណនេយ្យនិងសវនកម្ម, និងអចលនទ្រព្យ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ស្ថិតក្រោមការគ្រប់គ្រង, ត្រួតពិនិត្យ និងប្បញ្ញត្តិកម្មរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលមាននិយ័តករក្រោមឱវាទជាសេនាធិការធ្វើនិយ័តកម្មតាមអនុវិស័យនីមួយៗនៃសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ តាមបែបប្រពៃណីនេះ, ការគ្រប់គ្រង, ការត្រួតពិនិត្យ, និងប្បញ្ញត្តិកម្មសុទ្ធតែធ្វើឡើងដោយប្រតិបត្តិករកណ្តាល ឬអន្តរការី ដើម្បីធានាបាននូវការគ្រប់គ្រងហានិភ័យផ្សេងៗនិងធានាការទុកចិត្ត។យ៉ាងណាមិញ, ការងើបឡើងនូវបច្ចេកវិទ្យាថ្មីៗ, ដូចជាblockchain ឬdistributed ledger ជាដើមនៅក្នុងវិស័យហិរញ្ញវត្ថុបានធ្វើឱ្យមានការផ្លាស់ប្តូរស៊ីជម្រៅនៅក្នុងរបៀបនៃការគ្រប់គ្រងនិងធ្វើប្បញ្ញត្តិកម្មនេះឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការបាត់បង់នូវតួនាទីរបស់ប្រតិបត្តិករកណ្តាល ឬអន្តរការី ហើយដែលត្រូវបានហៅថាវិមជ្ឈការហិរញ្ញវត្ថុ (Decentralized Finance) ដូចជាទីផ្សាររូបិយវត្ថុគ្រីបតូ (Crypto currency market) ដែលកំពុងមានការទាក់ទាញនិងចាប់អារម្មណ៍ក្នុងរយៈពេល ប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយ, ឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជាសម្រេចបានសម្ទុះកំណើននិង បានចូលរួមកាន់តែខ្លាំងក្លាក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសតាមរយៈ ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ, ទាំងនៅទីប្រជុំជន និងជនបទ, ដែលជារួមត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការកើនឡើងយ៉ាងខ្លាំងនូវគ្រឹះស្ថានធនាគារ មីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ជាដើម ក្នុងវិសាលភាពវិស័យហិរញ្ញវត្ថុធនាគារ។ទន្ទឹមនឹងនេះ,អនុវិស័យផ្សេងៗនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារក៏បាន និងកំពុងចាប់ផ្តើមដុះលូតលាស់ជាបណ្តើរៗ ដែលនឹងមានសក្តានុពលខ្ពស់ក្នុងការទាញប្រយោជន៍សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិផងដែរ។ក្នុងន័យនេះ, ការបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក៏មានគោលដៅដើម្បីបង្កើតយន្តការស្ថាប័នច្បាស់លាស់និងមុតស្រួចក្នុងការដឹកនាំអភិវឌ្ឍវិស័យនេះឱ្យបានខ្លាំងក្លាថែមទៀត។ការរីកចម្រើននៃវិស័យនេះបានជំរុញឱ្យមានការទាក់ទាញក្នុងការបន្តវិនិយោគកាន់តែច្រើន លើបច្ចេកវិទ្យាហិរញ្ញវត្ថុជាពិសេសក្នុងការបង្កើនសេវាកម្មឬផលិតផលនវានុវត្តន៍និងការចាប់យកឱកាសថ្មីៗដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់អតិថិជន ឬអ្នកប្រើប្រាស់ជាពិសេសក្នុងចំណោមក្រុមអ្នកប្រើប្រាស់វ័យក្មេង។ ជាក់ស្តែង, នៅក្នុងវិបត្តិនៃជំងឺកូវីដ-១៩, ស្ថាប័នហិរញ្ញវត្ថុណាដែលចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាបានលឿន និងមុនគេ បានប្រែក្លាយវិបត្តិឱ្យទៅជាឱកាសថ្មីក្នុងការពង្រីកសេវារបស់ខ្លួនកាន់តែខ្លាំង និងមានភាពធន់ខ្ពស់ក្នុងការឆ្លើយតបទៅនឹងវិបត្តិនេះ។







ទន្ទឹមនេះ, បច្ចេកវិទ្យាហិរញ្ញវត្ថុបាន និងកំពុងផ្លាស់ប្តូរមុខមាត់នៃឧស្សាហកម្មហិរញ្ញវត្ថុ ទាំងមូលនៅក្នុងការផ្តល់និងការទទួលបានសេវាកម្មហិរញ្ញវត្ថុ, ដែលបានចូលរួមយ៉ាងសកម្មនិងខ្លាំងក្លាក្នុងការគាំទ្រ និងជំរុញកំណើនសេដ្ឋកិច្ច, តាមរយៈទិដ្ឋភាពចំនួន៤ធំៗរួមមាន÷

ទី១. បច្ចេកវិទ្យាហិរញ្ញវត្ថុអាចបង្កើនការប្រកួតប្រជែងដោយស្មើភាព និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាហិរញ្ញវត្ថុ ដោយសារការកាត់បន្ថយថ្លៃប្រតិបត្តិការ, ការសន្សំពេលវេលា និងការធ្វើឱ្យប្រសើរឡើងនូវការទទួលបានបទពិសោធន៍ថ្មី និងប្លែក ពីសំណាក់អ្នកប្រើប្រាស់;

ទី២. បច្ចេកវិទ្យាហិរញ្ញវត្ថុមានសក្តានុពលក្នុងការបង្កើតទីផ្សារថ្មី (new market segments) ដែលពង្រឹងទីផ្សារមានស្រាប់ ជាពិសេសបង្កើតឱ្យមានអន្តរទំនាក់ទំនង និងការផ្សារភ្ជាប់គ្នាកាន់តែជិតស្និទ្ធ រវាងសកម្មភាពហិរញ្ញវត្ថុនិងសកម្មភាពមិនមែនហិរញ្ញវត្ថុ (non-financial sectors) ដែលមានសក្តានុពលសម្រាប់ពន្លឿនប្រតិបត្តិការពិតប្រាកដ និងប្រតិបត្តិការអនឡាញ (real and online transactions)។ ការណ៍នេះមិនត្រឹមតែអាចបង្កើតឱកាសទីផ្សារថ្មីប៉ុណ្ណោះទេ ថែមទាំងអាចផ្តល់លទ្ធភាពក្នុងការបង្កើតប្រភពនៃកំណើនសេដ្ឋកិច្ចថ្មីផងដែរ;

ទី៣. បច្ចេកវិទ្យាហិរញ្ញវត្ថុ អាចពង្រីកបរិយាប័ន្នកម្មហិរញ្ញវត្ថុ (financial inclusion) ក្នុងទិដ្ឋភាពជាចលករសម្រាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ថ្នាលឌីជីថលដើម្បីទទួលបាននិងប្រើប្រាស់សេវា ហិរញ្ញវត្ថុផ្លូវការ ដល់ប្រជាជនក្រីក្រ និងពុំមានលទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុគ្រប់គ្រាន់

ទី៤. បច្ចេកវិទ្យាហិរញ្ញវត្ថុក៏មានតួនាទីសំខាន់ក្នុងការពង្រឹងនិងពង្រីកសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលជាប្រភពសំខាន់សម្រាប់បង្កើតនិងលើកកម្ពស់លក្ខខណ្ឌការងារនិងជំរុញកំណើនប្រកបដោយបរិយាប័ន្ន និងចីរភាព។

ចំណែកឯវិស័យហិរញ្ញវត្ថុវិមជ្ឈការគឺជាប្រព័ន្ធហិរញ្ញវត្ថុថ្មីមួយសម្រាប់បំពេញបន្ថែមទៅលើប្រព័ន្ធហិរញ្ញវត្ថុបែបប្រពៃណី, ហើយភាគច្រើនជាប្រតិបត្តិការលើហេដ្ឋារចនាសម្ព័ន្ធកិច្ចសន្យាឆ្លាតវៃ (Smart Contract) ដោយប្រើបច្ចេកវិទ្យាប្លុកឆេន (Blockchain) និងមិនមានគ្រឹះស្ថានហិរញ្ញវត្ថុជាអន្តរការីនោះឡើយ។

មកដល់ពេលនេះ, ការប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (Blockchain) សម្រាប់ទីផ្សាររូបិយវត្ថុគ្រីបតូ (Crypto currency market) ទោះបីជាមានភាពពុះកញ្ជ្រោលពីវិស័យឯកជន, រូបិយវត្ថុគ្រីបតូមិនបានទទួលស្គាល់ជាផ្លូវការដោយប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក។ត្រង់ចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ថា កន្លងមក, ធនាគារជាតិនៃកម្ពុជា រួមជាមួយនឹងគណៈកម្មការមូលបត្រកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដោយបានបញ្ជាក់ថាការផ្សព្វផ្សាយ, ចរាចរ, ទិញលក់ និងជួញដូរកាក់អេឡិចត្រូនិក ដោយមិនមានអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ចគឺជាសកម្មភាព ខុសច្បាប់។ ជាការពិត, ការហាមឃាត់នេះសំដៅតែលើការជួញដូរកាក់អេឡិចត្រូនិកប៉ុណ្ណោះ ប៉ុន្តែមិនមែនមានន័យថា មិនអនុញ្ញាតឱ្យប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេនសម្រាប់គោលដៅផ្សេងឡើយ។ ត្បិតថាវិស័យហិរញ្ញវត្ថុវិមជ្ឈការស្ថិតក្នុងភាពថ្មីស្រឡាង និងមិនទាន់មានការប្រើប្រាស់ ទូលំទូលាយនៅឡើយនៅកម្ពុជា, យើងត្រូវធ្វើការពិសោធន៍ដោយផ្ទាល់ និងសិក្សាស្វែងយល់ឱ្យបានកាន់តែច្បាស់លាស់ និងស៊ីជម្រៅដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមា និងកាត់បន្ថយហានិភ័យឱ្យស្ថិតក្នុងកម្រិតអប្បបរមាពីបច្ចេកវិទ្យាបែបនេះហើយដែលខ្ញុំរំពឹងថាគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យា

ហិរញ្ញវត្ថុនេះនឹងជួយកំណត់ទិសដៅនិងក្របខណ្ឌនៃការគ្រប់គ្រង បច្ចេកវិទ្យាបែបនេះបាននៅកម្ពុជា។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

ដោយផ្អែកលើបទពិសោធន៍និងការពិភាក្សារបស់អ្នកជំនាញ, អ្នករៀបចំគោលនយោបាយនិងអ្នកប្រតិបត្តិផ្ទាល់នៅក្នុងអង្គសិក្ខាសាលានេះ ខ្ញុំជឿជាក់យ៉ាងមុតមាំថា លទ្ធផលពីអ្វី ដែលអ្នកទាំងអស់គ្នានឹងពិភាក្សាឆ្លើយតបទៅនឹងសំណួរគោលនយោបាយមួយចំនួនដូចជា÷តើរដ្ឋាភិបាលមានតួនាទីដូចម្តេចក្នុងការជ្រោមជ្រែងនិងលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ?តើវិសាលភាពនៃការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវកំណត់ត្រឹមកម្រិតណា? តើត្រូវការរយៈពេលប៉ុន្មាន? តើវិស័យគន្លឹះណាខ្លះគួរត្រូវយកចិត្តទុកដាក់? និងសំខាន់ជាងនេះទៀត តើរដ្ឋាភិបាលត្រូវរៀបចំ ឬកែប្រែបទបញ្ញត្តិ និងយន្តការអនុវត្តការងារដូចម្តេចដើម្បីពង្រឹងប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិការងាររវាងស្ថាប័នពាក់ព័ន្ធសំដៅគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ, ជំរុញនវានុវត្តន៍ ក៏ដូចជាគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានពីបច្ចេកវិទ្យាថ្មីៗ? នៅក្នុងន័យនេះ, ខ្ញុំសូមគូសបញ្ជាក់និងទាញការយកចិត្តទុកដាក់លើចំណុចពាក់ព័ន្ធសំខាន់ៗមួយចំនួន ដើម្បីជាមូលដ្ឋានសម្រាប់ការពិចារណា និងតម្រង់ទិសការពិភាក្សារយៈពេល២ថ្ងៃនេះដូចខាងក្រោម÷

ទី១)- គួរកំណត់គោលការណ៍គន្លឹះក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយនេះឱ្យបានច្បាស់លាស់ ដោយ ម៉្យាង, ត្រូវរក្សាឱ្យបាននូវសង្គតិភាព ទៅនឹងទិសដៅនៃ គោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងក្របខណ្ឌគោល-នយោបាយពាក់ព័ន្ធដែលត្រូវបានដាក់ចេញ និងម៉្យាងទៀត, ត្រូវសំដៅដល់ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ, ការរក្សាលំនឹងនៃស្ថិរភាពហិរញ្ញវត្ថុនិងការបង្កើត និងបង្កើននវានុវត្តន៍ ក្នុងវិស័យហិរញ្ញវត្ថុ។

ទី២)- គួរពិនិត្យលើអភិក្រមពគីទទួលយក (Adopt), បន្សាំ(Adapt), និងនវានុវត្តបន្ថែម(Innovate further)។ សម្រាប់កម្ពុជាដែលជាប្រទេសតូច និងកំពុងអភិវឌ្ឍ, អភិក្រមនេះនិងផ្តល់ឱកាសឱ្យយើងអាចរៀនសូត្រដកស្រង់បទពិសោធន៍បន្សាំនិងកែសម្រួលដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ការធ្វើនវានុវត្តន៍។

ទី៣)- គួរត្រូតពិនិត្យ និងគិតគូរអំពីបទប្បញ្ញត្តិដែលអាចធានានូវគោលការណ៍ "សមភាព" ក្នុងការគ្រប់គ្រងអាជីវកម្មដែលប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុដើម្បីបង្កើតនូវសមាមាត្រ(Proportionality) នៃការធ្វើបញ្ញត្តិកម្មរវាងអាជីវកម្មខ្នាតធំនិងអាជីវកម្មខ្នាតតូចឬធុរកិច្ចថ្មី។គោល-ការណ៍សមាមាត្រនេះនឹងអនុញ្ញាតឱ្យអាជីវកម្មខ្នាតតូច និងថ្មីៗមានឱកាសចូលរួមដោយស្របច្បាប់ ក្នុងការផ្តល់សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុបាន។

ទី៤)- គួរកំណត់និងធ្វើបញ្ជីអាទិភាពឱ្យបានច្បាស់លាស់នូវគ្នាស់បច្ចេកវិទ្យាដែលត្រូវការចាំបាច់ជួយដល់ការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ដូចមានក្នុងរបាយការណ៍ឯកឧត្តមបណ្ឌិត **គង់ ម៉ារី**, យើងបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់គ្នាស់បច្ចេកវិទ្យាមួយចំនួនរួចហើយ ប៉ុន្តែខ្ញុំជឿថានៅមានគ្នាស់បច្ចេកវិទ្យាច្រើនទៀតដែលយើងត្រូវគិតគូររៀបចំឱ្យបានឆាប់រហ័ស។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

គោលនយោបាយអភិវឌ្ឍវិស័យបច្ចេក-វិទ្យាហិរញ្ញវត្ថុកម្ពុជានឹងក្លាយជាផ្នែកមួយដ៏សំខាន់នៃការកសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ,ការទាក់ទាញវិនិយោគក្នុងស្រុក និងក្រៅស្រុក, ការជំរុញការបង្កើតធុរកិច្ចថ្មី និងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការបង្កើនផលិតផល និងសេវាកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ, និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច។ ដើម្បីធានាបាននូវការរៀបចំសេចក្តីព្រាងគោលនយោបាយមួយដែលមានភាពប្រទាក់ក្រឡាមុតស្រួចនិងគ្រប់ជ្រុងជ្រោយ, ការបន្តប្រមូលធាតុចូលល្អៗឱ្យបានកាន់តែច្រើននិងជាក់លាក់ពីតួអង្គពាក់ព័ន្ធក្នុងវិស័យសំខាន់ៗនៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងដំណើរតាក់តែងសេចក្តីព្រាងគោល-នយោបាយនេះពិតជាមានភាពចាំបាច់។ ក្នុងន័យនេះ,ក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាត្រូវបន្តរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ទៅតាមអនុវិស័យអាទិភាពនៃវិស័យហិរញ្ញវត្ថុទាំងមូល។បន្ថែមលើនេះ, ខ្ញុំក៏សូមស្នើឱ្យគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដោយសហការជាមួយនិយ័តករទាំងអស់ទាំងក្នុងវិស័យធនាគារនិងមិនមែនធនាគារពិនិត្យលទ្ធភាពរៀបចំព្រឹត្តិការណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុប្រចាំឆ្នាំនៅកម្ពុជា ដែលជាវេទិកាថ្នាក់ជាតិ សម្រាប់បើកឱ្យមានការពិភាក្សា, ការចែករំលែក និងការផ្លាស់ប្តូរយោបល់ទូលំទូលាយពីគ្រប់តួអង្គពាក់ព័ន្ធ សំដៅប្រមូលកំណត់ឱ្យបាននូវបញ្ហាប្រឈម, កាលានុវត្តភាព និងដំណោះស្រាយបែបបច្ចេកវិទ្យាថ្មីដែលនឹងជួយដល់ការអនុវត្តគោលនយោបាយនេះកាន់តែមានប្រសិទ្ធភាពថែមទៀត។




ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, វិស័យឯកជនទាំងក្នុងផ្នែកធនាគារនិងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ,ធុរជន,និងនវានុវត្តជនដែលបានចូលរួមក្នុងសិក្ខាសាលានេះនឹងចូលរួមយ៉ាងសកម្មក្នុងការចែករំលែកចំណេះដឹង និងបទពិសោធន៍និងផ្តល់ជាធាតុចូល ដើម្បីបានជាទុនដ៏មានតម្លៃសម្រាប់ក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយក្នុងការចាប់ផ្តើមដំណើរ-ការអនុវត្តការងារ។ ជាងនេះទៅទៀត, ក្រុមការងារបច្ចេកទេសដែលជាសេនាធិការរបស់ក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ត្រូវអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារប្រកបដោយស្មារតីបុរេសកម្ម និង ការទទួល ខុសត្រូវខ្ពស់ ដើម្បីធានាបាននូវភាពជោគជ័យនៃការតាក់តែងសេចក្តីព្រាងគោលនយោបាយនេះ។

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!*

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរ-គុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ, តំណាងដៃគូអភិវឌ្ឍន៍, វិស័យឯកជនធនាគារ និងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, ធុរជន, និងនវានុវត្តជន ដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលានេះ។

ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំនិងក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាដែលបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរៀបចំសេចក្តីព្រាងគោលនយោបាយនេះឡើង។

ខ្ញុំសូមជូនពរឱ្យសិក្ខាសាលានេះដំណើរការប្រកបដោយផ្លែផ្កា ហើយសម្រេចបានលទ្ធផលតាមការរំពឹងទុក និងសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី នូវពុទ្ធពរទាំង ៤ ប្រការគឺ÷ អាយុ, វណ្ណៈ, សុខៈ, ពលៈ និងចៀសឆ្ងាយពីជំងឺកូវីដ-១៩ទាំងអស់គ្នា។

ខ្ញុំសូមប្រកាសបើកនូវសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី"គោល-នយោបាយនិងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា" ចាប់ពីពេលនេះតទៅ! សូមអរគុណ!

*រៀបចំដោយ÷ គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល*

# សុន្ទរកថាឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើគោលនយោបាយ និងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២

*- ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា,*

*- លោក, លោកស្រី, ភ្ញៀវជាតិ, និងអន្តរជាតិជាទីមេត្រី!*



នាពេលនេះសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើ“**គោលនយោបាយ និងទិសដៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា**” បានឈានមកដល់ទីបញ្ចប់ហើយ។ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ថាសិក្ខាសាលានេះបានប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។ ឆ្លៀតឱកាសនេះ,តាងនាមឱ្យខ្ញុំជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅនិងស្មោះស្ម័គ្រជូនចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹងចំពោះសិក្ខាសាលានេះនិងការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

ខ្ញុំសូមសម្តែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះ**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាវាគ្មិន**ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមផ្តល់ជាមតិយោបល់តាមរយៈការពិភាក្សាយ៉ាងផុលផុស ការលើកជាសំណួរនិងការផ្តល់ជាអនុសាសន៍ក៏ដូចជាការចែករំលែកនូវចំណេះដឹងឧត្តមានុវត្តន៍និងនវានុវត្តន៍ផ្សេងៗក្នុងរយៈពេលមួយថ្ងៃកន្លះនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ**ឯកឧត្តម, លោកជំទាវ, លោក លោកស្រី ភ្ញៀវជាតិ, និងអន្តរជាតិ** តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ស្ថានទូត, ដៃគូអភិវឌ្ឍន៍, វិស័យឯកជនធនាគារ និងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, និងធុរកិច្ចថ្មីដែលបានចូលរួមនៅទីនេះផ្ទាល់ក៏ដូចជាចូលរួមពីចម្ងាយតាមប្រព័ន្ធអនឡាញ។ការចូលរួមនេះគឺពិតជាចាំបាច់និងមានតម្លៃធំធេងណាស់។

ជាការពិតណាស់**សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី"គោលនយបាយ និងទិសដៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា"** បានបង្កើតឡើងជាវេទិកាដ៏មានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នាក្នុងការចូលរួមពិភាក្សា និងផ្លាស់ប្តូរមតិយោបល់ សំដៅស្វែងយល់ឱ្យកាន់តែច្បាស់និងស៊ីជម្រៅពីវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលនឹងចូលរួមចំណែកក្នុងការកំណត់ទិសដៅ គោលការណ៍ និងវិធានគោលនយោបាយក្នុងការតាក់តែងសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។ បន្ថែមលើនេះសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនេះក៏ជាជំហានចាប់ផ្តើមដ៏ល្អនៅក្នុងដំណាក់កាលដំបូងនៃការតាក់តែងសេចក្តីព្រាងគោលនយោបាយដែលមានលក្ខណៈប្រទាក់ក្រឡា, មុតស្រួច, គ្រប់ជ្រុងជ្រោយ,និងងាយបត់បែនប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន។

*ឯកឧត្តម, អ្នកឧកញ៉ា, លោកឧកញ៉ា, លោកជំទាវ, លោក, លោកស្រី!*

ឆ្លងកាត់សិក្ខាសាលាពិគ្រោះយោបល់រយៈពេលមួយថ្ងៃកន្លះនេះ, ខ្ញុំសូមធ្វើការសន្និដ្ឋានសរុបជារួមនូវខ្លឹមសារសំខាន់ៗដែលបានមកពីការចែករំលែកឧត្តមានុវត្តន៍ការធ្វើបទបង្ហាញពីប្រធានបទពាក់ព័ន្ធ និងការជជែកពិភាក្សាក្នុងសិក្ខាសាលានេះ ដូចខាងក្រោម÷

**ទី១**. តាមរយៈ “**ការចែករំលែកបទពិសោធនៃការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ**”របស់ប្រទេសក្នុងតំបន់ទាំង៤ រួមមានប្រទេសសិង្ហបុរី,ថៃ,ឥណ្ឌូណេស៊ី,និងហ្វីលីពីន,យើងឃើញថាប្រទេសទាំងនោះមាន ការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ខ្លាំងលើការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។នេះមិនមែនជារឿងដែលគួរឱ្យភ្ញាក់ផ្អើលនោះទេ ដោយហេតុថាបច្ចេកវិទ្យានេះ ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ឱ្យអ្នកប្រើប្រាស់ ក៏ដូចជាសេដ្ឋកិច្ចឌីជីថល។ ប្រទេស សិង្ហបុរី, ថៃ, ឥណ្ឌូណេស៊ី និងហ្វីលីពីន ត្រូវបានចាត់ទុកថាជាប្រទេសដែលមាន ការអភិវឌ្ឍខ្លាំងក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងចំណោមប្រទេសក្នុងតំបន់។ ឈរលើមូលដ្ឋាននេះ, ឧត្តមានុវត្តន៍នៃការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុរបស់ប្រទេសទាំងនេះអាចផ្តល់នូវគុណតម្លៃជាច្រើនសម្រាប់កម្ពុជាយកមកប្រើប្រាស់ដើម្បីបង្កើនសម្ទុះក្នុងការអភិវឌ្ឍវិស័យនេះក្នុងប្រទេសដោយគោរពតាមអភិក្រមរបស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** គឺការទទួលយក (Adopt), ការសម្របតាម(Adapt) និងការបង្កើតនវានុវត្តន៍បន្ថែមទៀត (Innovate Further)។

**ទី២**. តាមរយៈការធ្វើបទបង្ហាញ និងការពិភាក្សាពី“ការវិវត្តចុងក្រោយនិងបញ្ហាប្រឈមនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ” យើងសង្កេតឃើញថាវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាពិតជាមានភាពរីកចម្រើនលឿនគួរឱ្យកត់សម្គាល់ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុធនាគារ។ ប៉ុន្តែទន្ទឹមនឹងនេះយើងក៏សង្កេតឃើញផងដែរថាកម្ពុជាប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងការអភិវឌ្ឍលើវិស័យនេះដែលកត្តាប្រឈមទាំងនោះរួមមានដូចជា កង្វះក្របខណ្ឌបទប្បញ្ញត្តិ, កង្វះទេពកោសល្យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យនេះ, ព្រមទាំងកង្វះនៃការគាំទ្រគន្លឹះជំរុញការអនុវត្តឌីជីថលជាដើម។ទោះជាយ៉ាងនេះក៏ដោយ កម្ពុជាក៏ជាប្រទេសដែលមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុផងដែរ។

**ទី៣**. តាមរយៈការធ្វើបទបង្ហាញ និងការពិភាក្សាពី“អក្ខរកម្មឌីជីថល, អក្ខរកម្មហិរញ្ញវត្ថុ, និងការគាំទ្រការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ” យើងឃើញថាចំណេះដឹងផ្នែកឌីជីថល និងហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ភាគច្រើននៅមានកម្រិតទាបនៅឡើយនៅក្នុងប្រទេស។ អក្ខរកម្មឌីជីថលនិងអក្ខរកម្មហិរញ្ញវត្ថុជាមូលដ្ឋានគ្រឹះចាំបាច់បំផុត ដើម្បីឱ្យអ្នកប្រើប្រាស់អាចប្រើប្រាស់ផលិតផលនិងសេវាកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុបានយ៉ាងមានប្រសិទ្ធភាព, អាចជៀសផុតពីការក្លែងបន្លំពីជនខិលខូច និងកំហុសឆ្គងផ្សេងៗក្នុងការប្រើប្រាស់។ទោះជាយ៉ាងនេះក៏ដោយយើងអាចឃើញមានពន្លឺជាវិជ្ជមានច្រើនដោយសារអ្នកពាក់ព័ន្ធជាពិសេសស្ថាប័នអប់រំចាប់ផ្តើមយល់ដឹងពីតម្រូវការ និងសារៈសំខាន់នៃចំណេះដឹងផ្នែកឌីជីថលនិងហិរញ្ញវត្ថុហើយចាប់ផ្តើមរៀបចំកម្មវិធីសិក្សាដែលអាចឆ្លើយតបនឹងតម្រូវការទាំងនោះបាន។ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុដែលមជ្ឈមណ្ឌលនេះនឹងដើរតួយ៉ាងសំខាន់ក្នុងការសិក្សាពីឧត្តមានុវត្តន៍អន្តរជាតិរៀបចំនិងស្នើឡើងនៃផែនការឬបទបញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុសំដៅជំរុញការអភិវឌ្ឍវិស័យនេះ។

**ទី៤**. តាមរយៈការធ្វើបទបង្ហាញនិងការពិភាក្សាពី“តួនាទីរបស់និយ័តករក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ” យើងសង្កេតឃើញថានិយ័តករមានតួនាទីសំខាន់ណាស់ ក្នុងការពង្រឹងនិងធានាប្រសិទ្ធភាពនៃការគ្រប់គ្រងត្រួតពិនិត្យនិងអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុរួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យនេះ។ ហេតុនេះការពង្រឹង និងបង្កើននូវសមត្ថភាពរបស់និយ័តករលើវិស័យនេះពិតជាមិនអាចខ្វះបានឡើយ។

កន្លងមក ធនាគារជាតិនៃកម្ពុជាបានតាក់តែងផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ(២០២០-២០២៥)ដែលផ្តោតជាសំខាន់លើវិស័យ




ហិរញ្ញវត្ថុធនាគារ និងមានវិសាលភាពអនុវត្តគ្របដណ្តប់លើគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារ។ការតាក់តែងផែនទីបង្ហាញផ្លូវនេះបានសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការចូលរួមអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេស។ប៉ុន្តែដើម្បីពន្លឿនការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសទាមទារនូវក្របខណ្ឌគោលនយោបាយរួមមួយដែលមានភាពប្រទាក់ក្រឡា និងសព្វជ្រុងជ្រោយ សំដៅជួយឱ្យអ្នកពាក់ព័ន្ធនៃវិស័យនេះធ្វើការជាមួយគ្នានៅក្នុងកម្រិតថ្នាក់ជាតិបាន។ សរុបជារួមចំណេះដឹងនិងទស្សនាទានទាំងអស់ដែលបានមកពីការចែករំលែកឧត្តមានុវត្តន៍ការធ្វើបទបង្ហាញពីប្រធានបទពាក់ព័ន្ធនិងការជជែកពិភាក្សាក្នុងសិក្ខាសាលានេះនឹងផ្តល់ជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំតាក់តែងសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

*ឯកឧត្តម, អ្នកឧកញ៉ា, លោកឧកញ៉ា, លោកជំទាវ, លោក, លោកស្រី!*

ខ្ញុំសូមអនុញ្ញាតគូសរំលេចបន្ថែមដោយសង្ខេបនូវសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដែល ឯកឧត្តម **គង់ ម៉ារី** អនុប្រធានក្រុមការងារ ទើបបានធ្វើបទបង្ហាញមុននេះបន្តិច÷

**ទី១.** គោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជានឹងផ្តោតទៅលើសកម្មភាពនៅក្នុងវិស័យទាំង៣ រួមមាន÷(១) វិស័យហិរញ្ញវត្ថុធនាគារ (Bank), (២) វិស័យហិរញ្ញវត្ថុមិនមែនធនាគារ (Non-Bank) និង (៣) វិស័យហិរញ្ញវត្ថុវិមជ្ឈការ (Decentralized Finance)។គោលនយោបាយនេះនឹងដើរស្របជាមួយមូលដ្ឋាននៃគោលនយោបាយហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗពោលគឺសំដៅឱ្យឆ្លើយតបនឹងគោលការណ៍៣រួមមាន÷ (១) លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាស្នូល (Promote Financial Inclusion), (២) រក្សាលំនឹងនៃស្ថិរភាពហិរញ្ញវត្ថុ (Balance Financial Stability), និង (៣) បង្កើននវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុ (Nurture Financial Innovation)។

**ទី២.** គោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជានឹងកំណត់យកក្របខណ្ឌអភិវឌ្ឍរួមចំនួន ៤ រួមមាន÷ (១) កត្តាជំរុញជាគោលនយោបាយ (Policy Enablers) ដែលអាចជាបទបញ្ញត្តិ, ការការពារទិន្នន័យ និងការផ្តល់អាជ្ញាបណ្ណ, (២) កត្តាជំរុញការអនុវត្តឌីជីថល (Digital Enablers) ដែលអាចជាថ្នាលឌីជីថលដែលដើរតួនាទីសម្របសម្រួលឱ្យបច្ចេកវិទ្យាឬថ្នាលឌីជីថលដទៃទៀតអាចកសាង និងធ្វើដំណើរការបានរលូន, (៣) កត្តាជំរុញបច្ចេកវិទ្យា (Enabling Technologies) ដែលអាចជាបច្ចេកវិទ្យាថ្មីៗប្រើប្រាស់ដោយធុរកិច្ចថ្មី, និង (៤) សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Activities) ដែលអាចជាអាជីវកម្មហិរញ្ញវត្ថុទាំងឡាយណាដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាស្នូល។

*ឯកឧត្តម, អ្នកឧកញ៉ា, លោកឧកញ៉ា, លោកជំទាវ, លោក, លោកស្រី!*

ខ្ញុំសូមគូសបញ្ជាក់ថា បើទោះជាមានការកំណត់គោលការណ៍និងក្របខណ្ឌនៃការអភិវឌ្ឍ ដែលខ្ញុំទើបលើកឡើងនេះក៏ដោយ, ការរៀបចំគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាគឺទើបតែស្ថិតនៅដំណាក់កាលចាប់ផ្តើមនៅឡើយ ដែលយើងបើកទូលាយក្នុងការទទួលយកធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ។ លទ្ធផលដែលទទួលបានក្នុងសិក្ខាសាលានេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាក្នុងដំណាក់កាលចាប់ផ្តើមនេះ។បន្ថែមពីលើនេះ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនសម្រាប់ជាយន្តការបន្តក្នុងការរៀបចំតាក់តែងសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាដែលមានដូចតទៅ÷

**ទី១.** បន្តការសិក្សាស្រាវជ្រាវស្វែងយល់ពីស្ថានភាព និងការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ទាំងនៅកម្ពុជា និងសាកលលោក ដើម្បីបានជាគោលគំនិត និងទស្សនទានសំខាន់ៗ ដាក់បញ្ចូលក្នុងគោលនយោបាយ។ខ្ញុំសូមគាំទ្រចំពោះការលើកឡើងរបស់ ឯកឧត្តម **គង់ ម៉ារី** អនុប្រធានក្រុមការងារពីផែនការក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយដោយដាក់បញ្ចូលការសិក្សាស្រាវជ្រាវជាអាទិភាព។ក្នុងនោះការធ្វើទស្សនកិច្ចសិក្សាទៅតាមបណ្តាប្រទេសមួយចំនួនដែលមានការរីកចម្រើនខ្លាំងក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក៏មានសារៈសំខាន់ផងដែរដើម្បីក្រុមការងារអាចរៀនសូត្របានពីឧត្តមានុវត្តន៍និងនវានុវត្តន៍ផ្សេងៗ។ ដូចនេះសូមក្រុមការងារយកចិត្តទុកដាក់ធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅលម្អិត និងច្បាស់លាស់ដើម្បីធានាថាសេចក្តីព្រាងគោលនយោបាយនេះនឹងក្លាយជាឯកសារគោលយ៉ាងសំខាន់មួយសម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេស។

**ទី២.** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ស្ថានទូត, ដៃគូអភិវឌ្ឍន៍, វិស័យឯកជនធនាគារ និងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, និងធុរកិច្ចថ្មី ក្នុងរូបភាពជាសិក្ខាសាលា កិច្ចប្រជុំតូចធំ ឬកិច្ចពិភាក្សាដើម្បីធានាបាននូវធាតុចូលពីគ្រប់ដៃគូពាក់ព័ន្ធ។ខ្ញុំគាំទ្រចំពោះការលើកឡើងរបស់ឯកឧត្តមអនុប្រធានក្រុមការងារចំពោះការសហការជាមួយដៃគូពាក់ព័ន្ធក្នុងការរៀបចំសិក្ខាសាលាលើវិស័យមួយចំនួនដូចជាក្នុងវិស័យធានាគារវិស័យធានារ៉ាប់រងនិងវិស័យហិរញ្ញវត្ថុវិមជ្ឈការជាដើម។ខ្ញុំសូមលើកទឹកចិត្តឱ្យពិនិត្យមើលលទ្ធភាពបន្ថែមក្នុងការរៀបចំវេទិកា ឬកិច្ចប្រជុំជាមួយវិស័យពាក់ព័ន្ធមួយចំនួនទៀតក្នុងគោលបំណងប្រមែប្រមូលធាតុចូលពីវិស័យទាំងនោះ។ ការចូលរួមពីដៃគូពាក់ព័ន្ធ និងការប្រមូលធាតុចូលបានកាន់តែច្រើនកាន់តែធានាបានថាគោលនយោបាយដែលរៀបចំឡើងអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ដៃគូពាក់ព័ន្ធ។ ជាងនេះទៅទៀត យើងក៏អាចធានាបាននូវការរៀបចំគោលនយោបាយមួយដែលមានលក្ខណៈប្រទាក់ក្រឡា, មុតស្រួច, គ្រប់ជ្រុងជ្រោយ និងងាយបត់បែនប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន។

**ទី៣.** សម្រាប់យន្តការធ្វើការងារ, ក្រុមការងារបច្ចេកទេសជាសេនាធិការឱ្យក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមានចំនួន៤÷

(១) ក្រុមការងារបច្ចេកទេសទទួលបន្ទុកបូកសរុប, (២) ក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុធនាគារ, (៣) ក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, និង (៤) ក្រុមការងារបច្ចេកទេសទទួលបន្ទុក



បច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យហិរញ្ញវត្ថុវិមជ្ឈការ។ ខ្ញុំសូមឱ្យក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវរៀបចំការប្រជុំជាមួយគ្នាជាប្រចាំដោយយកអភិក្រមជួបប្រជុំរៀងរាល់សប្ដាហ៍ ប្រសិនជាអាចទៅរួច។

សម្រាប់ក្រុមការងារបច្ចេកទេសទទួលបន្ទុកបូកសរុបត្រូវធ្វើការឱ្យស្និទ្ធស្នាលជាមួយក្រុមការងារបច្ចេកទេសពផ្សេងទៀត ហើយកំណត់យកអភិក្រមជួបជុំគ្នារៀងរាល់ ២សប្ដាហ៍ម្ដងដើម្បីប្រមូលធាតុចូលពីក្រុមការងារបច្ចេកទេសនីមួយៗ។ខ្ញុំជឿជាក់ថាការកំណត់អភិក្រមបែបនេះនឹងជួយឱ្យកិច្ចការរៀបចំគោលនយោបាយមានវឌ្ឍនភាពជាប្រចាំ និងធានាសម្រេចបាននូវសេចក្ដីព្រាងគោលនយោបាយចុងក្រោយនៅចុងឆ្នាំ២០២២ នេះ ដូចដែលបានកំណត់ក្នុងផែនការសកម្មភាព។

*ឯកឧត្តម, អ្នកឧកញ៉ា, លោកឧកញ៉ា, លោកជំទាវ, លោក, លោកស្រី!*

មុននឹងបញ្ចប់ខ្ញុំសូមទាញចំណាប់អារម្មណ៍បន្ថិចថាកត្តាជោគជ័យលើការរៀបចំតាក់តែងសេចក្ដីព្រាងគោលនយោបាយនិងអនុវត្តគោលនយោបាយគឺតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ដៃគូពាក់ព័ន្ធ។

ដូចនេះ ខ្ញុំសូមអំពាវនាវឱ្យគ្រប់ដៃគូពាក់ព័ន្ធទាំងអស់បន្តចូលរួមចំណែកផ្ដល់កិច្ចសហការនិងគាំទ្របន្ថែមទៀតដល់ការរៀបចំតាក់តែងសេចក្ដីព្រាងគោលនយោបាយនិងអនុវត្តគោលនយោបាយនេះនាថ្ងៃខាងមុខ។ ជាថ្មីម្ដងទៀត តាងនាមឱ្យខ្ញុំជាប្រធានក្រុមការងាររៀបចំសេចក្ដីព្រាងគោលនយោបាយនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងនិងការប្ដេជ្ញាចិត្តខ្ពស់របស់ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ហើយខ្ញុំមានក្ដីសង្ឃឹមយ៉ាងមុតមាំចំពោះការចូលរួមចំណែករបស់យើងទាំងអស់គ្នា ក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។

ជាទីបញ្ចប់ខ្ញុំសូមបួងសួងដល់វត្ថុស័ក្ដិសិទ្ធិទាំងអស់ក្នុងលោក និងទេវតាឆ្នាំថ្មី ជូនពរបវរសួស្ដី សិរីមង្គល មានលាភ មានជ័យមហាប្រសើរជូន ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ទាំងអស់ ឱ្យសម្រេចបានជោគជ័យការងារមានសុភមង្គលគ្រប់ក្រុមគ្រួសារនិងជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើ“ គោលនយោបាយនិងទិសដៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា” ចាប់ពីពេលនេះតទៅ៕

*រៀបចំដោយ៖ គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល*





# ផ្នែកទី ៤

# ទស្សនៈនិងគតិ





ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានទទួលលទ្ធផលល្អប្រសើរដែលបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបង្វែរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាព បង្កើននូវធនធានវិនិយោគសាធារណៈ អាចសន្សំ លើកស្ទួយឯករាជ្យភាពផ្នែកថវិការបស់កម្ពុជានិងអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយដើម្បីជួយប្រជាជននិងវិស័យឯកជនដែលបាននិងកំពុងបន្តទទួលរងនូវផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។ក្នុងន័យនេះ ការអនុវត្តដោយជោគជ័យនូវគោលដៅធំៗរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជានាពេលអនាគត។

***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** *ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២២ ក្រោមប្រធានបទ "ការស្តារកម្ពុជាឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ ÷ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព បន្ទាប់ពីជំងឺកូវីដ-១៩" សណ្ឋាគារសុខាភ្នំពេញ, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២។*



"តាមរយៈ**គោលនយោបាយឈ្នះ-ឈ្នះ**និងក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ប្រទេសកម្ពុជាបានចាកផុតពីសង្គ្រាមរ៉ាំរ៉ៃដែលបានអូសបន្លាយជាច្រើនទសវត្សព្រមទាំងទទួលបានយ៉ាងពេញលេញនូវសុខសន្តិភាពការបង្រួបបង្រួមជាតិ, ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលបន្តមានមហិច្ឆតាកាន់តែខ្ពស់បន្ថែមទៀតគឺការប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបឱ្យក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវមហិច្ឆតាទាំងនេះ, ការអភិវឌ្ឍនិងការកែទម្រង់លើគ្រប់វិស័យគឺជាកត្តាចាំបាច់ ដែលក្នុងនោះ ការកសាងប្រព័ន្ធគាំពារសង្គមដ៏រឹងមាំមួយ គឺជាសសរស្តម្ភដ៏សំខាន់ក្នុងការចូលរួមលើកកម្ពស់ និងអភិវឌ្ឍកត្តាមនុស្សដែលជាកត្តាអាទិភាពមួយក្នុងចំណោមកត្តាអាទិភាពទាំង ៤ សម្រាប់ការអភិវឌ្ឍជាតិ ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពោលគឺ÷ មនុស្ស, ផ្លូវ, ទឹក និងភ្លើង។"

*អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងសុន្ទរកថាក្នុងពិធីបើក "ទិវាសប្តាហ៍គាំពារសង្គម" ប្រចាំឆ្នាំ២០២២ នៅសណ្ឋាគារ Hyatt Regency ភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២។*





*កន្លងមក រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រឹងក្របខណ្ឌ គតិយុត្ត ដើម្បីជំរុញឱ្យមានការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការពារអ្នកប្រើប្រាស់ផងដែរ ។ លិខិតបទដ្ឋានគតិយុត្តទាំងនោះមានទម្រង់ជាអនុក្រឹត្យ និងប្រកាស ដែលមានដូចជាអនុក្រឹត្យស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, អនុក្រឹត្យស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន, ប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់, ប្រកាសស្តីពីគម្រោងវិនិយោគរួម, និងប្រកាសស្តីពីការគ្រប់គ្រង គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ជាដើម។ ជាងនេះទៅទៀត, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងប្រព័ន្ធអេកូឡូហ្ស៊ីក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ចាំបាច់ត្រូវមានភាពរឹងមាំផងដែរ។*

*ឯកឧត្តមបណ្ឌិត**គង់ ម៉ារី** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ថ្លែងសុន្ទរកថារាយការណ៍ក្នុង "សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើគោលនយោបាយ និងទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា" នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។*



*បរិយាបន្នហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ថាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជាការបង្រួមគម្លាតសង្គមការបង្កើននវានុវត្តន៍នៅក្នុងសង្គមដែលជាកាតាលីករយ៉ាងសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ក្នុងបរិការណ៍នេះយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌជាគោលនយោបាយជាតិនិងជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ដែលមានផែនការសកម្មភាពគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់និងទ្រទ្រង់ដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយមានស្ថិរភាពប្រសិទ្ធភាពនិងពិពិធកម្មទីផ្សារហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន។ជាមួយគ្នាផងដែរសេវាទូទាត់សងប្រាក់មានការរីកចម្រើនគួរឱ្យកត់សម្គាល់និងបានវិវឌ្ឍន៍ទៅរកការទូទាត់បែបឌីជីថលដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនជាពិសេសសហគ្រាសធុនតូចនិងមធ្យមលើសេវាទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ងាយស្រួលសុវត្ថិភាពនិងចំណាយតិច។ ជាមោទនភាពជាតិផងដែរ ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេនបានអនុញ្ញាតិឱ្យអ្នកប្រើប្រាស់អាចធ្វើការទូទាត់ និងផ្ទេរប្រាក់ភ្លាមៗពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយ តាមរយៈកម្មវិធីធនាគារនៅលើទូរស័ព្ទដៃប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព។*

*លោកជំទាវបណ្ឌិត**ជា សិរី** ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជាថ្លែងក្នុងសិក្ខាសាលាតម្រង់ទិសអំពី "កម្មវិធីលទ្ធភាពទទួលបានហិរញ្ញវត្ថុ" នៅសណ្ឋាគារ អូឡាំពា្យស៊ីធី និងតាមប្រព័ន្ធអនឡាញ, ថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ៖

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វីណែល | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |

## រៀបចំអត្ថបទដោយ ៖

### ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| រិទ្ធី សត្រា | មន្ត្រីជំនាញ |
| ស៊ុន គឹមហេង | មន្ត្រីជំនាញ |

### ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| គង់ ឆោមកែវវលក្ខណ៍ | មន្ត្រីជំនាញជាន់ខ្ពស់ |
| គុណ មុនីរ័ត្នភ្លង | មន្ត្រីជំនាញ |
| ចាន់ ផាន់ណា | មន្ត្រីជំនាញ |
| ធន សិទ្ធិកា | មន្ត្រីជំនាញ |

### ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| រិទ្ធ រតនៈ | មន្ត្រីជំនាញ |

### ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| រស់ ដាលីន | មន្ត្រីជំនាញជាន់ខ្ពស់ |
| ជា សុខផេង | មន្ត្រីជំនាញជាន់ខ្ពស់ |

### ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ែន | មន្ត្រីជំនាញជាន់ខ្ពស់ |
| ផែង សុខម៉ៃ | មន្ត្រីជំនាញជាន់ខ្ពស់ |
| អ៊ូ ចិន្តា | មន្ត្រីជំនាញ |

### ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ួច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកថវិកា |
| ឈុន ម៉ារឌី | មន្ត្រីជំនាញផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | មន្ត្រីជំនួយការផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ឡេង ចាន់ភ្លួង | មន្ត្រីជំនួយការផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

### ការចូលរួមផ្សេងៗ៖

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានពន្ធដារ
ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

## នវានុវត្តន៍ និងកែសម្រួលដោយ ៖

### ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| គង់ ឆោមកែវវលក្ខណ៍ | មន្ត្រីជំនាញជាន់ខ្ពស់ |
| គុណ មុនីរ័ត្នភ្លង | មន្ត្រីជំនាញ |
| ចាន់ ផាន់ណា | មន្ត្រីជំនាញ |
| ធន សិទ្ធិកា | មន្ត្រីជំនាញ |

ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំខណ្ឌដូនពេញ
រាជធានីភ្នំពេញ កម្ពុជា។

(+៨៥៥) ៨៥ ៧៧៧ ៩២៤

www.pfm.gov.kh

www.facebook.com/gscpfm

gsc@pfm.gov.kh

ទាញយកព្រឹត្តិបត្រ